ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 01-Mar-2016, 11:54
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៦**

**ម៉ោង ០៩:០៦នាទី**

**សវនាការលើកទី៣៧២**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

កញ្ញា អេវេលីន ខាំផូស សង់ចេស
*(Ms. Evelyn CAMPOS SANCHEZ)*

លោក ឯម ហ៊ុយ

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង ប៊ុនឃាង

កញ្ញា សុង ឆវ័ន្ត

លោក ឌេល លីសាក់ *(Mr. Dale Lysak)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍

*(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក ឡេា ជុនធី

លោក ហុង គឹមសួន

លោក វ៉េន ពៅ

លោកស្រី ទី ស្រ៊ីនណា

លោកស្រី ស៊ីន សុវ៉ន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

លោកស្រី សួ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| លោក ខេល លីសាក់ | អង់គ្លេស |
| លោក សុន អរុណ | ខ្មែរ |
| លោកស្រី អង់តា ហ្គីសសេ | បារាំង |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៦:៤៨]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយសវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្ដាប់ការដាក់បង្ហាញឯកសារគន្លឹះ ដែលនឹងធ្វើដោយសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីបញ្ចប់ ហើយនិងដោយក្រុមសហមេធាវីការពារក្ដី ខៀវ សំផន ពាក់ព័ន្ធទៅនឹងអង្គហេតុ ការប្រព្រឹត្តទៅលើក្រុមមនុស្សគោលដៅជាក់លាក់ចំនួនបី គឺចំពោះជនជាតិចាម ចំពោះជនជាតិវៀតណាម និងចំពោះអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ។ ហើយប៉ុន្តែដោយសារមានបញ្ហាបន្តិចបន្តួចកាលពីម្សិលមិញនេះគឺក្រឡាបញ្ជីសវនាការបានទទួលសំណើសុំពីតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ បានស្នើសុំពេលវេលាបន្ថែមពីអង្គជំនុំជម្រះដើម្បីដាក់បង្ហាញឯកសារគន្លឹះ ពាក់ព័ន្ធនឹងអង្គហេតុនៃការប្រព្រឹត្តទៅលើអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ។ ហើយអង្គជំនុំជម្រះ នឹងធ្វើការពិនិត្យលើសំណើសុំនេះមុន មុននឹងធ្វើនីតិវិធីនៃការផ្ដល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី និងក្រុមសហមេធាវីការពារក្ដី នួន ជា -- ខៀវ សំផន ក្នុងការដាក់បង្ហាញឯកសារគន្លឹះរបស់ខ្លួនចំពោះមុខអង្គជំនុំជម្រះ។

ក្រឡាបញ្ជីសវនាការ លោក ឯម ហ៊ុយ ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

[០៩:០៩:១២]

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្ដីនេះ មានវត្តមាន។ លើកលែងតែមេធាវីការពារក្ដីឲ្យលោក នួន ជា គឺលោក វ៉ិចទ័រ កូប៉េ អវត្តមានដោយគ្មានមូលហេតុ។ ដោយឡែក លោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោម

សាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើស្នើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនា-ការនេះ របស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៦ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ចង់បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនៅថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់ចូលរួម និងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការ នៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៦។

មេធាវីការពារក្តីរបស់ខ្លួនបានប្រាប់អំពីផលប៉ះពាល់នៃការលះបង់សិទ្ធិនេះថា ការលះបង់នេះមិនអាចកបស្រាយថាជាការលះបង់សិទ្ធិរបស់ខ្លួនក្នុងការកាត់សេចក្តីដោយយុត្តិធម៌ ឬក៏សិទ្ធិក្នុងការជំទាស់ក្នុងការត -- ភស្តុតាងក្នុងដាក់បង្ហាញ ឬដាក់ជូនតុលាការនេះ គ្រប់ពេលវេលានៃសវនាការលើរូបខ្លួនឡើយ។

[០៩:១០:៥៧]

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យព្យាបាល ថែទាំសុខភាពជនជាប់ចោទ នៅអ.វ.ត.ក ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៦។ បានកំណត់សម្គាល់ពីស្ថានភាពសុខភាពរបស់លោក នួន ជា នៅថ្ងៃនេះថាមានអាការៈឈឺចង្កេះជាប្រចាំ និងការឈឺកាន់តែខ្លាំងនៅពេលអង្គុយយូរ និងបានផ្តល់អនុសាសន៍ថា សូមឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់មួយស្ថិតនៅក្រោមសាលសវនាការនេះ។ ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥)នៃវិធានផ្ទៃក្នុងអ.វ.ត.ក អង្គជំនុំជម្រះអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការនៅក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការសម្រាប់

ថ្ងៃនេះ។

បាទ មុននឹងបន្តនីតិវិធីតទៅទៀតនោះគឺអង្គជំនុំជម្រះសូមជម្រាបថា កាលពីរសៀលម្សិលមិញនេះ អង្គជំនុំជម្រះបានទទួលសំណើសុំពីតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ថាខ្លួនមានបំណងស្នើសុំពេលវេលាបន្ថែមពីអង្គជំនុំជម្រះដើម្បីដាក់បង្ហាញឯកសារគន្លឹះមួយចំនួន ពាក់ព័ន្ធទៅនឹងអង្គហេតុនៃការប្រព្រឹត្តទៅអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ហើយដើម្បីឲ្យមានភាពច្បាស់លាស់លើបញ្ហានេះ ទាំងសំណើសុំ និងទាំងមូលហេតុ ឬក៏សំអាងហេតុទាំងឡាយនៃការស្នើសុំនេះ អង្គជំនុំជម្រះសូមផ្តល់ជូនទៅតំណាងសហព្រះរាជអាជ្ញាអន្តរជាតិដើម្បីធ្វើសំណើ និងបញ្ជាក់បង្ហាញពីសំអាងហេតុនៃការស្នើសុំនេះ។

[០៩:១២:៥០]

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោក លោកស្រីចៅក្រម។

សូមទោសដែលខ្ញុំបង្ហាញមិនបានច្បាស់កាលពីម្សិលមិញ។ អ្វីដែលយើងស្នើសុំការផ្តល់ពេលវេលាពាក់ព័ន្ធទៅនឹងជនជាតិចាម និងជនជាតិវៀតណាម គឺថាប្រធានបទមួយដ៏ធំ ហើយនៅពេលដែលលោក ស្មីត លើកឡើងពីម្សិលមិញនេះ គឺពាក់ព័ន្ធទៅនឹងការប្រព្រឹត្តមកលើមន្ត្រីរបបសាធារណរដ្ឋ លន់ នល់ និងទាហានរបបលន់ នល់។

ដូច្នេះ យើងខ្ញុំអាចអនុវត្តទៅសំណើសុំ ដោយអនុលោមតាមវិធាន៩២ នៃវិធានផ្ទៃក្នុងនៅពេលក្រោយបាន។ ហើយបើសិនណាអនុញ្ញាតឲ្យខ្ញុំថ្ងៃនេះ គឺថាខ្ញុំសូមពេលតែ៤០នាទីទេ។ គឺខ្ញុំផ្តោតទៅលើប្រធានបទ ពាក់ព័ន្ធទៅនឹងសក្ខីកម្មរបស់សាក្សី ដែលលើកឡើងពាក់ព័ន្ធទៅនឹងការចោទប្រកាន់ក្នុងរយៈពេលពីរខែ ក្រោយថ្ងៃ១៧ មេសា ១៩៧៥ មកលើទាហានរបបលន់ នល់។ ដូច្នេះ ជាថ្មីម្តងទៀត គឺថាសំណើសុំនេះ គឺអាចអនុញ្ញាតឲ្យខ្ញុំលើកឡើងនៅពេលក្រោយក៏បាន ដោយសារតែកាលវិភាគសម្រាប់ថ្ងៃនេះ គឺថាហាក់បីដូចជាមានពេលចង្អៀតសម្រាប់ភាគីដទៃទៀត។

ជាការពិតហើយ ដែលថាមានឯកសារសំខាន់ពាក់ព័ន្ធទៅនឹងប្រធាបបទដែលយើងខ្ញុំស្នើសុំ ហើយក៏ជួយដល់អង្គជំនុំជម្រះក្នុងការស្វែងយល់ ក៏ដូចជាជួយដល់ភាគីដទៃទៀតៗផងដែរ។ ហើយសំណើសុំនេះ ដោយសារតែឯកសារដែលយើងខ្ញុំចង់បង្ហាញនេះ គឺវាមានសារៈសំខាន់បំផុតសម្រាប់ភាគីទាំងអស់ ក៏ដូចជាសម្រាប់អង្គជំនុំជម្រះ។

*(សម្រាករយៈពេលខ្លី)*

[០៩:១៥:២១]

**ប្រធានអង្គជំនុំ៖**

បាទ ហើយចុះភាគីដទៃមានមតិយោបល់អ្វីទេ លើសំណើសុំរបស់តំណាងសហព្រះរាជអាជ្ញាអន្តរជាតិក្នុងការស្នើសុំពេលវេលា ក្នុងការដាក់បង្ហាញឯកសារគន្លឹះមួយចំនួន ពាក់ព័ន្ធជាមួយនឹងអង្គហេតុទាំងឡាយនៃការប្រព្រឹត្តទៅលើអតីតទាហាននៃរបបសាធារណរដ្ឋខ្មែរ ដែលគាត់បានបង្ហាញអម្បាញ់មិញនេះ។

ដំបូងនេះ ផ្ដល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី តើមានមតិយោបល់កត់សម្គាល់អ្វីដែរទេ លើសំណើសុំនេះ?

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម សម្រាប់ខាងមេធាវីនាំមុខមិនមានអ្វីជាការជំទាស់ទៅដល់សំណើសុំរបស់សហព្រះរាជអាជ្ញាទេ ហើយថ្ងៃនេះ យើង -- សម្រាប់ខាងយើងខ្ញុំគឺយើងត្រូវការតែរយៈពេលខ្លីទេ ដូច្នេះ ខ្ញុំគិតថាវាមិនប៉ះពាល់ទេ លើកលែងតែមានយោបល់អ្វីផ្សេងពីខាងការពារក្ដី។

**ប្រធានអង្គជំនុំ៖**

ចុះក្រុមសហមេធាវីការពារក្ដីលោក នួន ជា តើមានមតិយោបល់អីទេ?

**លោក សុន អរុណ៖**

សូមគោរពលោកប្រធាន សូមគោរពអង្គសវនាការ ខាងក្រុមលោក នួន ជា ពុំមានអ្វីស្នើសុំទេ។

**ប្រធានអង្គជំនុំ៖**

ចុះក្រុមមេធាវីការពារក្ដីលោក ខៀវ សំផន?

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំសូមអភ័យទោសលោកប្រធាន ខ្ញុំអត់បានស្ដាប់ឮការបកប្រែនូវអ្វីដែលលោកមេធាវី សុន អរុណ បាននិយាយទេ។ ក៏ប៉ុន្តែគោលជំហររបស់លោក ខៀវ សំផន គឺថាយើងបាន -- យើងជំទាស់ក្នុងការលើកឡើង និយាយពីគោលនយោបាយដែលទាក់ទងនឹងយោធារបបសាធារណរដ្ឋ។ អ៊ីចឹង ក៏ប៉ុន្តែយើងមិនជំទាស់ទៅលើសេចក្ដីពន្យល់របស់សហព្រះរាជអាជ្ញាទេ គឺថាដោយសារគាត់បាននិយាយថាមានកម្រិតទេ គាត់មិនលើកច្រើនទេ ក៏ប៉ុន្តែយើងសូមរក្សាលទ្ធភាពនៅពេលដែលយើងឆ្លើយតបនោះ

សូមលទ្ធភាព សុំពេលវេលាបន្ថែម ដើម្បីឆ្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញានេះវិញ។

[០៩:១៧:៤២]

**ប្រធានអង្គជំនុំ៖**

បាទ បើដូច្នេះ គឺអង្គជំនុំជម្រះអនុញ្ញាតតាមសំណើសុំរបស់តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ក្នុងការផ្តល់ពេលវេលាបន្ថែម៤០នាទី តាមសំណើសុំក្នុងការបង្ហាញឯកសារគន្លឹះពាក់ព័ន្ធជាមួយនឹងប្រធានបទចំពោះ -- អនុវត្តចំពោះគោលដៅជាក់លាក់ ចំពោះអតីតទាហាននៃរបបសាធារណរដ្ឋខ្មែរក្រោយឆ្នាំ១៩៧៥។ សូមអញ្ជើញបាទ!

**លោក ពេជ អង្គ៖**

លោកប្រធាន តើខាងសហព្រះរាជអាជ្ញាចាប់ផ្តើមការបង្ហាញរបស់គាត់ ឬក៏ទុកឲ្យខាងខ្ញុំបង្ហើយកិច្ចការរបស់ខ្ញុំសិន?

**ប្រធានអង្គជំនុំ៖**

អរគុណ បើសិនជាលោកមានបំណងធ្វើដូច្នេះក៏បានដែរ ដើម្បីបញ្ចប់មួយទៅ ព្រោះមិនមានពាក់ការពាក់ព័ន្ធគ្នា ខ្វែងគ្នាអ្វីទេ រវាងភាគីទាំងពីរ។

បាទ ឥឡូវអង្គជំនុំជម្រះផ្តល់ សម្រេចផ្តល់តាមសំណើសុំរបស់លោកចុះ។

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម ភាគីសាធារណជន និងដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំនឹងបន្តការអានព័ត៌មានរបស់ដើមបណ្តឹងរដ្ឋប្បវេណីចំនួនប្រាំមួយបន្ថែម។ សង្ឃឹមថានឹងបញ្ចប់ក្នុងរយៈ១០នាទី ឬក៏លើសនេះបន្តិចបន្តួច។

ដើមបណ្តឹងរដ្ឋប្បវេណី -- ព័ត៌មានរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលជាការសម្ភាស កិច្ចសម្ភាសន៍របស់គាត់ និងមន្ត្រីស៊ើបអង្កេតរបស់សាលាក្តីខ្មែរក្រហម គឺលោកដើមបណ្តឹងរដ្ឋប្បវេណី ដួ យ៉ាំងអ៊ូន ដែលមានលេខឯកសារ E3/5587 ដែលមាន ERN ជាភាសាខ្មែរ 00416802 ដល់ 03, ជាភាសាអង់គ្លេស 00426466 ដល់ 68, ជាភាសាបារាំង 00455405 ដែលខ្ញុំសូមស្រង់កិច្ចសម្ភាសន៍របស់គាត់ដូចតទៅ៖

[០៩:២០:០៨]

“សំណួរ៖ សូមលោកបញ្ជាក់ពីព្រឹត្តិការណ៍ដែលបងប្អូន និងឪពុកម្តាយរបស់លោកត្រូវបានចាប់

យកទៅសម្លាប់? ឆ្លើយ៖ នៅយប់ថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ គ្រួសាររបស់ខ្ញុំទាំងអស់ត្រូវបានជម្លៀសចេញ យើងត្រូវបានហាមឃាត់មិនឲ្យយកអីវ៉ាន់ទៅជាមួយដោយបានប្រាប់ថា ពេលស្ងាត់ចាំមកវិញ ចាំយកមកវិញ ព្រោះខ្លាច លន់ នល់ យកយន្តហោះមកទម្លាក់គ្រាប់បែក។ នៅថ្ងៃមួយ ពួកខ្ញុំកំពុងទៅលើកទំនប់ ឪពុកម្ដាយនៅផ្ទះ បងៗទៅកងចល័ត។ ពេលខ្ញុំមកផ្ទះវិញ ខ្ញុំឃើញផ្ទះស្ងាត់ អ្នកជិតខាងដែលជាជនជាតិវៀតណាមដូចគ្នាប្រាប់ខ្ញុំថា ឪពុកម្ដាយ និងបងប្អូនខ្ញុំត្រូវបានយកទៅសម្លាប់ ខ្ញុំត្រូវបានពួកគាត់យកទៅលាក់។ សំណួរ៖ ហេតុដូចម្ដេចបានជាជនជាតិវៀតណាមដូចគ្នា ដែលបានប្រាប់ដំណឹងដល់លោកនោះមិនត្រូវបានគេយកទៅផងដែរ? ឆ្លើយ៖ នៅពេលដែលខ្ញុំទៅដល់វៀតណាម ពួកអ្នកជិតខាង ទាំងនោះបានប្រាប់ខ្ញុំថា មកពីគ្រួសារខ្ញុំត្រូវបានគេចោទថាជាទាហានវៀតកុង ទើបត្រូវគេយកទៅសម្លាប់។ គ្រួសារខ្ញុំមិនមានអ្វីពាក់ព័ន្ធនឹងវៀតកុងទេ។ អ្នកជិតខាងក៏បានប្រាប់ខ្ញុំផងដែរថា ឪពុកម្ដាយ និងបងប្អូនខ្ញុំត្រូវបានជនជាតិខ្មែរដែលជាអ្នកមូលដ្ឋានចាស់ក្នុងព្រៃ បររទេះយកទៅភូមិក្លួយ ឃុំដារ ស្រុកកំពង់លែង ក្រោមបញ្ជារបស់ តាអោក និង តាពាង។ តាពាង គឺជាអ្នកគ្រប់គ្រងថ្នាក់ស្រុកកំពង់លែង។ ពួកអ្នកគ្រប់គ្រងនេះគឺជាអ្នកកាន់បញ្ជីឈ្មោះប្រជាជនតាំងពីយូរមកហើយ ដូច្នេះគេដឹងអ្នកណាជាអ្នកណា។ សំណួរ៖ សូមលោករៀបរាប់អំពីដំណើររឿងរបស់លោកទៅវៀតណាម? ឆ្លើយ៖ ពួកខ្ញុំត្រូវបានប្រាប់ថា ស្អែកឡើងកុំទៅធ្វើការ ដោយមិនប្រាប់ពីមូលហេតុអ្វីទាំងអស់។ ថ្ងៃនោះ គឺប្រជាជនគ្រប់ភូមិដែលជាជនជាតិវៀតណាមបានមកប្រជុំនៅឃុំត្រង់ភ្នំឃារ ដែលមានមេឃុំឈ្មោះ តាប៊ិន, តាអោក, តាម៉ុង, តាម៉ាត់ ចូលរួម ហើយប្រកាសថា ពួកខ្ញុំត្រូវបានវៀតណាមទទួលយកទៅស្រុកវិញ។ មេឃុំក៏បាននិយាយផងដែរថា ថ្នាក់លើខាងខ្មែរក្រហមក៏បានព្រមព្រៀងដែរ។ នៅឃុំផ្សេងទៀតក៏មានប្រជុំដូចគ្នាដែរ ហើយក៏មានទាំងថ្នាក់ដឹកនាំស្រុកចូលរួមផងដែរ។ លុះម៉ោងបួនទៀបភ្លឺទើបប្រជាជនត្រូវដើរទៅមាត់កំពង់ ត្រង់កំពង់ហៅ ក្នុងស្រុកកំពង់លែង។ អ្នកដែលដើរនៅក្រោយគេ ពេលមកជួបជុំគ្នាលើសាឡាង់បានប្រាប់ខ្ញុំថា អ្នកនៅក្រោយត្រូវបានប្លន់យករបស់របរ។ ខ្ញុំឃើញមានសាឡាង់ប្រហែលប្រាំពីរទៅប្រាំបី។ ប្រជាជនប្រហែល ២០០នាក់ត្រូវដាក់ក្នុងមួយសាឡាង់។ ដូច្នេះ អ្នកខ្លះត្រូវដាក់ជាន់ក្រោម ត្រូវហប់ខ្យល់ស្លាប់នៅតាមផ្លូវ។ នៅលើសាឡាង់មានខ្មែរក្រហមស្លៀកពាក់ខ្មៅ ពាក់មួកកន្ទិប និងកាន់កាំភ្លើង។ នៅពេលទៅដល់ក្អមសំណ ប្រជាជនត្រូវបានហៅឡើងកោះធំមួយនៅទល់ដែន។ នៅទីនោះ ខ្ញុំបានឃើញមន្ត្រីវៀតណាមឈ្មោះ ង្វៀង យ៉ាងាំង ហៅ ទីកាម និយាយប្រាប់ខ្ញុំថា ពួកខ្ញុំត្រូវបានដូរជាមួយអំបិល។ ឪពុកខ្ញុំ និងពូៗរបស់ខ្ញុំធ្លាប់និយាយនិងស្គាល់ពីឈ្មោះ ទី កាម នេះដោយគាត់ជាអ្នក

គ្រប់គ្រងជនជាតិវៀតណាមនៅកម្ពុជា។ នៅកោះនោះ ចាស់ៗបានប្រាប់ខ្ញុំថា នោះហើយគឺ ទី កាម។ វៀតណាមដែលមកទទួលមិនដឹងជាមន្ត្រីកម្រិតណាទេ តែស្លៀកពាក់ស៊ីវិល។ សំណួរ៖ នៅពេលដែលប្រជុំ ដើម្បីចេញដំណើរមកវៀតណាម តើប្រជាជនមានជម្រើស ឬក៏ត្រូវតែធ្វើតាមបញ្ជា? ឆ្លើយ៖ មិនមានអ្នកណាហ៊ានតវ៉ាទេ។ សួរ៖ ចំពោះការជ្រើសរើសនៅក្អមសំណា តើត្រូវបានធ្វើដូចម្តេច? ឆ្លើយ៖ ប្រជាជនត្រូវតម្រៀបជួរគ្នា ចូលកន្លែងត្រួតពិនិត្យម្តងម្នាក់ ដែលនៅក្នុងនោះ មានតែមន្ត្រីវៀតណាមសុទ្ធ។ បើអ្នកណាវៀតណាម មិនទទួល ខ្មែរក្រហមចាំទទួលយកទៅវិញ នៅខាងក្រៅ។ មានប្តី ឬប្រពន្ធដែលជាខ្មែរ ត្រូវបានហាមឃាត់មិនឲ្យទៅជាមួយគ្នាជាគ្រួសារទេ។ ចំពោះខ្មែរក្រហម បានធ្វើការជ្រើសរើសនៅភ្នំយារ នោះរួចហើយ ដោយនៅភ្នំនោះ ប្រជាជនខ្មែរនៅផ្សេង ហើយប្រជាជនវៀតណាមនៅផ្សេង។ ចំពោះអ្នកនៅភ្នំយារ ដែលបានមកដល់ក្អមសំណានេះ ត្រូវបានច្រឡំ ឬបន្លំមកជាមួយគ្រួសារ ដើម្បីបានទៅវៀតណាមជាមួយគ្នា។ សួរ៖ ចំពោះមន្ត្រីត្រួតពិនិត្យនៅក្អមសំណានោះ តើខាងវៀតណាម ឬខ្មែរដែលមានច្បាប់តឹងរ៉ឹងមិនឲ្យប្តី ឬប្រពន្ធដែលជាខ្មែរទៅជាមួយនោះ? ឆ្លើយ៖ ខ្ញុំឃើញថាមន្ត្រីខាងវៀតណាមតឹងរ៉ឹងជាង។ ខ្ញុំមិនបានដឹងពីកិច្ចព្រមព្រៀងរវាងខ្មែរក្រហម និងវៀតណាមដូចម្តេចនោះទេ។”

[០៩:២៦:៣៧]

ខ្ញុំសូមរំលងទៅសំណួរទី១០បន្តទៀត ខ្ញុំសូមដកស្រង់៖ “សំណួរ៖ នៅពេលនៅក្អមសំណា តើគេមានធ្វើតេស្តភាសាដែរឬទេ? ឆ្លើយ៖ នៅក្នុងការត្រួតពិនិត្យនោះ មន្ត្រីវៀតណាមមើលតែសម្បុរ និងភាសានិយាយ ហើយបើអ្នកណាដូចខ្មែរទាល់តែមានបងប្អូនដែលមកជាមួយគ្នានោះ ធានាថាជាក្មួយ ឬក៏ជាកូនបង្កើតទើបអាចទៅបាន។ អ្នកដែលទៅនោះ មិនមានបងប្អូនមកពីវៀតណាមមកទទួលទេ។ នៅក្អមសំណានេះ មិនមានមន្ត្រីខាងខ្មែរក្រហមត្រួតពិនិត្យទៅលើភាសា ឬជនជាតិទៀតទេ ពីព្រោះបានរៀបចំជាបញ្ជី ឬក៏ស្គាល់រួចស្រេចនៅភ្នំយាររួចទៅហើយ។”

ខ្ញុំសូមបញ្ជាក់ថា មានឯកសារដើមបណ្តឹងរដ្ឋប្បវេណីដែលនិយាយអំពីការធ្វើដំណើរ ការបង្ខំឲ្យចាកចេញទៅវៀតណាមដូចនឹងដើមបណ្តឹងរដ្ឋប្បវេណីដែលខ្ញុំទើបតែអានអម្បាញ់មិញដែរ គឺដើមបណ្តឹងរដ្ឋប្បវេណី ឡឺ យ៉ាងស្វ ដែលមានលេខឯកសារ E3/5626 ហើយឯកសារដដែលនេះត្រូវបានដាក់លេខមួយទៀត គឺលេខ E3/4574។ ហើយក៏មានដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ទៀតឈ្មោះ--

**ប្រធានអង្គជំនុំ៖**

កុំៗអាលទាន់ កុំអាលទាន់។ អញ្ជើញៗលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ ខ្ញុំសូមការបំភ្លឺមួយទាក់ទងនឹងឯកសារដែលលោកកំពុងតែអានហ្នឹង។ បាទៗ សូមបញ្ជាក់ថា តើជាកំណត់ហេតុស្ដាប់ចម្លើយ មិនមែនជាពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីទេ ហើយតើវាមាននៅក្នុងបញ្ជីរបស់លោកដែរឬទេ ហើយដែលថា ជាឯកសាររបស់បុគ្គលម្នាក់ដែលស្លាប់ហើយហ្នឹងឬក៏មិនមែនទេ?

[០៩:២៨:៤៥]

**លោក ពេជ អង្គ៖**

បាទ សូមគោរពចៅក្រម ឡាវែន៍។ នេះ គឺជាកិច្ចសម្ភាសន៍របស់ដើមបណ្ដឹងរដ្ឋប្បវេណីជាមួយមន្ត្រីនៃការិយាល័យចៅក្រមស៊ើបអង្កេត។ លោក ដួ យ៉ាំងអួន បានស្លាប់រួចទៅហើយ។ ខ្ញុំសង្ឃឹមថា ខ្ញុំបានឆ្លើយនឹងសំណួររបស់លោកចៅក្រម។

បាទ អ៊ីចឹងឯកសារដែលនិយាយដូចគ្នានេះ គឺៗកិច្ចសម្ភាសន៍របស់ដើមបណ្ដឹងរដ្ឋប្បវេណីលោក ត្រាំង យ៉ឹងយ៉ុង ដែលលោក ត្រឹង យ៉ាំងយ៉ុង នេះ ក៏បានស្លាប់ទៅហើយដែរ ហើយឯកសាររបស់គាត់ គឺលេខ E3/5588។ ខ្ញុំនឹងមិនអានឯកសារទាំងពីរនេះទេ ដោយសារនឹងមានលក្ខណៈច្រំដែលច្រើនហើយព័ត៌មាននិយាយអំពីបញ្ហាបញ្ជូនវៀតណាមទៅប្រទេសវិញ ហើយដូចគ្នា។

ខ្ញុំចូលទៅដល់ព័ត៌មានរបស់ដើមបណ្ដឹងរដ្ឋប្បវេណីជាបន្តបន្ទាប់ទៀត ដែលសូមដកស្រង់ខ្លីៗដែលនិយាយអំពីការសម្លាប់ជនជាតិវៀតណាមនៅព្រៃវែង និងអំពើប្រឆាំងទៅនឹងជនជាតិវៀតណាមឬផ្សេងៗទៀត។ បាទ ដើមបណ្ដឹងរដ្ឋប្បវេណី -- ពាក្យសុំរបស់ដើមបណ្ដឹងរដ្ឋប្បវេណីរបស់លោកស្រីឆាយ អ៊ាត លេខ E3/6088។ លោកស្រីនិយាយអំពីព្រឹត្តិការណ៍ទៅប្ដីគាត់ ឈ្មោះ ជា ជឿន ដែលកើតឡើងនៅជិតឆ្នាំ៧៦ និង១៩៧៧ នៅឃុំស្វាយជ្រំ ស្រុកមេសាង ខេត្តព្រៃវែង។ ហើយERN ដែលខ្ញុំនឹងដកស្រង់គឺជាភាសាខ្មែរ លេខ 00503242, ជាភាសាអង់គ្លេស 01137799, ជាភាសាបារាំង មិនមានទេ ក៏ប៉ុន្តែបានស្នើសុំការបកប្រែរួចហើយ។ ដូចឯកសារមុនៗដែលខ្ញុំបានអានជូនអម្បាញ់មិញ សុទ្ធ-- ឯកសារនេះ គឺនៅក្នុងបញ្ជីដែលបានបញ្ជូនមកលោក លោកស្រីចៅក្រម ហើយនិងភាគីរួចទៅហើយ។ ដូច្នេះ ខ្ញុំសូមដកស្រង់ដូចតទៅ៖

[០៩:៣១:២៦]

“នៅខែកក្កដា ឆ្នាំ១៩៧៦ ស៊ុន វ៉ាត ជាប្រធានគណៈកងភូមិតូច ទ្រា -- គណៈកងតូចភូមិទ្រា បានចាប់ប្តីរបស់ខ្ញុំឱ្យនៅជាប់ប្រមូលអ្នកទោស ជាមួយ តាទន់ អ្នកផ្សេងទៀតភ្លេចឈ្មោះ។ ហើយ ស៊ុន វ៉ាត ជាគណៈកងភូមិតូច ភូមិទ្រា -- គណៈកងតូច ភូមិទ្រា បានហៅប្តីខ្ញុំឈ្មោះ ជា ជឿន ឱ្យនៅបែកពីខ្ញុំ ពេលឃើញ ឬក៏ជួបគ្នា ពុំដែលបាននិយាយទាក់ទងគ្នាឡើយ។ ហើយសមមិត្ត ស៊ុន វ៉ាត បានឱ្យប្តីខ្ញុំធ្វើការយ៉ាងធ្ងន់ធ្ងរ ដូចជា ដកស្ទូង ភ្ជួររាស់ រែកដី ជីកដី ធ្វើជីគ្មានសម្រាក។ ហូបមិនឆ្អែត ហូបតែបបររាវៗ ធ្ងន់ធ្ងរជាងអ្នកទោសដទៃទៀត។ ខែឧសភា ឆ្នាំ១៩៧៧ ប្តីរបស់ខ្ញុំ ជា ជឿន ត្រូវបានខ្មែរក្រហមសម្លាប់។ មុនដំបូង ស៊ុន វ៉ាត ដែលជាប្រធានកងតូចភូមិទ្រា បានចោទប្តីខ្ញុំជាខ្មាំង ជាភ្នាក់ងារយួន ទាំងខ្លួនពុំដឹងអ្វីតែសោះ។ មុនដំបូង ឈ្មោះ ស៊ុន វ៉ាត ដែលជាប្រធានកងតូចភូមិទ្រា បានចោទប្តីខ្ញុំជាខ្មាំង ជាភ្នាក់ងាយួន--” សូមទោស សូមអានម្តងទៀត “មុនដំបូង ស៊ុន វ៉ាត ដែលជាប្រធានកងតូចភូមិទ្រា បានចោទប្តីខ្ញុំជាខ្មាំង ជាភ្នាក់ងារយួន ទាំងខ្លួនពុំដឹងអ្វីទាល់តែសោះ ហើយ ស៊ុន វ៉ាត បានឱ្យប្តីខ្ញុំទៅចូលរួមប្រជុំនៅវត្តស្វាយជ្រំ ភូមិស្វាយជ្រំ ឃុំស្វាយជ្រំ ស្រុកមេសាង ខេត្តព្រៃវែង ជាមួយអ្នកប្រមូលផ្តុំផ្សេងទៀត (ភ្លេចឈ្មោះ)។ ពេលទៅដល់ពួកទាហានអាវខ្មៅពុំស្គាល់ឈ្មោះ បានចាប់ប្តីខ្ញុំវាយសួរចម្លើយ៥០ខ្សែតី សួរម្តង។ ដោយពួកគេនិយាយថា ឱ្យតែឆ្លើយសារភាព នោះពួកគេលែងវាយហើយ ឱ្យទៅនៅផ្ទះវិញ។ ដោយទារុណកម្មយ៉ាងធ្ងន់ធ្ងរពុំអាចទ្រាំបាន ប្តីខ្ញុំក៏សារភាពថា ជាភ្នាក់ងារយួន ទាំងខ្លួនពុំដឹងអ្វីទាល់តែសោះ។ ហើយនៅខែនោះ ខែឧសភា ឆ្នាំ១៩៧៧ ពួកដែលពាក់អាវខ្មៅ ខោអាវខ្មៅ ពាក់មួកកន្តិបកាន់កាំភ្លើងគ្រប់ដៃ (ពុំស្គាល់ឈ្មោះ) បានទទួលបញ្ជាពី ស៊ុន វ៉ាត ជាប្រធានគណៈកងតូចភូមិទ្រា បានបណ្តើរប្តីខ្ញុំចេញពីសហករណ៍ច្រេសក្បុត ភូមិច្រេស ឃុំច្រេស ស្រុកមេសាង ខេត្តព្រៃវែង ទៅទួលជើងចាប ភូមិសព័រ ឃុំព្រៃទទឹង ស្រុកមេសាង ខេត្តព្រៃវែង។ ពួកដែលនាំប្តីខ្ញុំទៅនោះ បានវាយសម្លាប់ប្តីខ្ញុំនៅទីនោះ ហើយក៏បាត់ខ្លួនគាត់តាំងពីថ្ងៃនោះរហូតមកដល់បច្ចុប្បន្ន។ នេះបើតាម តាទន់ ជាអ្នកប្រាប់ខ្ញុំ។ តែបច្ចុប្បន្ននេះ តាទន់ នេះស្លាប់ហើយ។”

[០៩:៣៤:៣០]

ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ទៀត ដែលមានពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់គាត់មានលេខ E3/6049 គឺលោកស្រី យ៉ឹង យ៉ង់។ លេខឯកសារដែលខ្ញុំដកស្រង់ គឺជាភាសាខ្មែរ មានលេខ ERN 00500852-53, ជាភាសាអង់គ្លេស 01137773, ជាភាសាបារាំង មិនមានទេ តែបានស្នើសុំបក

ប្រែរួចហើយ។ ខ្ញុំសូមដកស្រង់ដូចតទៅ៖ "ខែមិថុនា ឆ្នាំ១៩៧៦ អ៊ុល យឹង ដែលជាឪពុកបង្កើតរបស់ខ្ញុំ ត្រូវបានឈ្មោះ ម៉ៅ ប៊ិច ដែលជាប្រធានសហករណ៍ភូមិដុំ បាននាំឪពុកខ្ញុំទៅមន្ទីរសន្តិសុខទួលព្រៃអង្គរ ស្ថិតនៅក្នុងភូមិផ្អក ឃុំពានរោង ស្រុកព្រៃវែង ខេត្តព្រៃវែង។ ឪពុកខ្ញុំ អ៊ុល យឹង កាលមុនពេល ម៉ៅ ប៊ិច ចាប់យកទៅ គាត់ត្រូវបាន ម៉ៅ ប៊ិច នេះឲ្យគាត់ទៅធ្វើការនៅកន្លែងរោងសិប្បកម្មមួយក្នុងភូមិដុំជាមួយចាស់ៗ។ ម៉ៅ ប៊ិច ឲ្យធ្វើល្អី កញ្ច្រែង ចង្អេរ រនាស់ នង្គ័ល បង្កី ដោយគ្មានថ្ងៃសម្រាកឡើយ។ តាមពេលនៃតម្រូវការរបស់ប្រើប្រាស់។ ស្រាប់តែដល់ខែមិថុនា ឆ្នាំ១៩៧៦ ឪពុកខ្ញុំ អ៊ុជ យឹង ត្រូវបានគេហៅទៅមន្ទីរសន្តិសុខទួលព្រៃអង្គរ ប្រហែលម៉ោងបួនល្ងាច ដោយចោទគាត់ថា ជាយួន ជាជនជាតិយួន។ តែតាមពិតទៅ ឪពុកខ្ញុំជាជនជាតិខ្មែរសុទ្ធសាធតាំងពីដូនតាមកម្ល៉េះ។ តាំងពីថ្ងៃដែលនាំ -- ដែលឪពុកខ្ញុំបញ្ជូនទៅមន្ទីរសន្តិសុខទួលព្រៃអង្គរ ក្នុងភូមិផ្អក ឃុំពានរោង ដើម្បីរៀនសូត្រមក ឪពុកខ្ញុំ (អ៊ុជ យឹង) បាត់ដំណឹងសូន្យឈឹងរហូត។"

[០៩:៣៧:០២]

ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ទៀត មានឈ្មោះ ស៊ុំ សុត ដែលខ្ញុំសូមស្រង់ ERN នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរបស់ -- ដើមបណ្តឹង -- ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់គាត់ ដែល ERN ជាភាសាខ្មែរមានលេខ 00501122 ដល់ 23, ERN អង់គ្លេស 01137782, ERN ជាភាសាបារាំង 01155136 ដែលខ្ញុំសូមដកស្រង់ដូចតទៅ៖

"ហុង ហេន ដែលជាប្តីខ្ញុំ ពេលខ្មែរក្រហមចូលមកដល់កាន់កាប់អំណាច គាត់ត្រូវបានតា អៀប អឿង, តាកឹង បង្ខំឲ្យធ្វើការយ៉ាងធ្ងន់ធ្ងរគ្មានពេលសម្រាក។ លើសពីនេះទៅទៀត នៅខែវិច្ឆិកា ឆ្នាំ១៩៧៦ ប្តីខ្ញុំ (ហុង ហេន) ត្រូវបាន អៀប អឿង, តាកឹង ចោទប្រកាន់ថា ក្បាលយួនខ្លួនខ្មែរ គឺថាចង់បះបោរ ដែលខ្លួនគាត់ពុំដឹងអ្វីទាល់តែសោះ ហើយ អៀប អឿង, តាកឹង ក៏បានបញ្ជូនគាត់ទៅនៅក្នុងវត្តភ្លៀត ភូមិភ្លៀត ឃុំស្វាយជ្រំ ស្រុកមេសាង ខេត្តព្រៃវែង គឺជាប់ប្រមូលផ្តុំ (ជាប់ទោស) ដោយមិនឲ្យទាក់ទងអ្វីជាមួយបងប្អូនកូនចៅឡើយ។ បើជួបគ្នាធ្វើដូចមិនស្គាល់ទើបបានសុខ ហើយប្តីខ្ញុំក៏បាន អៀប អឿង, តាកឹង បង្ខំឲ្យធ្វើការយ៉ាងធ្ងន់ធ្ងរតាមអ្វីដែលគេត្រូវការ ដូចជា ដកស្ទូង រែក បោកបែន ច្រូតកាត់ លើកដីជាមួយអ្នកប្រមូលផ្តុំផ្សេងទៀត ដូចជា តាសោម តាយ៉ាន និង ជាច្រើនទៀត (ភ្លេចឈ្មោះ)។ ម្នាក់ៗខំប្រឹងធ្វើការអស់ពីកម្លាំងកាយចិត្ត ដើម្បីបញ្ជាក់ថា ខ្លួនស្អាតស្អំ និងបានរួចទោស។ ខែកុម្ភៈ ឆ្នាំ១៩៧៧ ប្តីខ្ញុំ ហុង ហេន ត្រូវបាន អៀប អឿង, តាកឹង បញ្ជូនទៅកន្លែងមន្ទីរឃុំស្វាយជ្រំ ទាំងយប់

ដែលនៅភូមិស្វាយជ្រំ ឃុំស្វាយជ្រំ ស្រុកមេសាង ខេត្តព្រៃវែង។ ពេលទៅដល់ទីនោះ គាត់ថា ខ្មែរក្រហមបានវាយសួរចម្លើយយ៉ាងធ្ងន់ធ្ងរដោយសន្តិសុខមិនស្គាល់ឈ្មោះ នៃមន្ទីរឃុំឃាំងស្វាយជ្រំហើយសួរថា ឯងជាភ្នាក់ងារសម្ងាត់របស់យួនមែនឬ? គ្នាឯងមានអ្នកណាខ្លះ? តែគាត់បដិសេធថា គាត់មិនមែនជាភ្នាក់ងារសម្ងាត់របស់យួនទេ។ គាត់មិនបានដឹងទេ។ បន្ទាប់មកខ្មែរក្រហមបានឲ្យប្ដីខ្ញុំរែកដីលុះដល់ពេលយប់វាយសួរចម្លើយបន្ត។ ខ្មែរក្រហមវាយសួររហូត តែប្ដីខ្ញុំឆ្លើយ បើមិនឆ្លើយមិនឈប់វាយទេ។ ដោយប្ដីខ្ញុំទ្រាំលែងបាន ក៏ចេះតែឆ្លើយផ្ដេសផ្ដាសដាក់ទៅលើអ្នកដែលទើបស្លាប់។ ហើយខ្មែរក្រហមបានឲ្យគាត់លត់ដំ ដោយរែកដីនៅទីនោះជាមួយអ្នកប្រមូលផ្ដុំផ្សេងៗទៀត ដូច តាសោម, តាយាន និងអ្នកផ្សេងទៀតៗដែលពុំចាំឈ្មោះអស់ជារយៈពេលជាយូរខែ។ ចប់នៅទីនោះ ខ្មែរក្រហមបានបញ្ជូនប្ដីខ្ញុំ ហុង ហេន ឲ្យមកចាក់លូ ធ្វើលូ នៅឈើទាលក្នុងភូមិក្បាលខ្វែក ឃុំស្វាយជ្រំ ស្រុកមេសាង ខេត្តព្រៃវែងវិញ។ ខាងមិថុនា ឆ្នាំ១៩៧៨ ប្ដីខ្ញុំបានរួចមកនៅផ្ទះពុំបានប៉ុន្មានថ្ងៃផង គាត់ត្រូវបានកងផលិតភូមិត្នោតឈ្មោះ តានាន បានហៅគាត់ទៅបើកសម្លៀកបំពាក់នៅវត្តជីផុច នៅភូមិជីផុច ឃុំជីផុច ស្រុកមេសាង ខេត្តព្រៃវែង។ ថ្ងៃនោះ ប្ដីខ្ញុំ តាសោម, តាយាន បានចេញទៅទាំងព្រឹកជាមួយអ្នកប្រមូលផ្ដុំផ្សេងៗទៀត(មិនចាំឈ្មោះ) ហើយក៏បានបាត់ខ្លួនគាត់ តាសោម, តាយាន តាំងពីថ្ងៃនោះមក ក្នុងខែមិថុនា ឆ្នាំ១៩៧៨។ បើតាមអ្នកភូមិជីផុចថា (មិនចាំឈ្មោះគាត់ទេ) អ្នកដែលប្រមូលផ្ដុំដែលខ្មែរក្រហមហៅទៅវត្តជីផុច ភូមិជីផុច ឃុំជីផុច នោះត្រូវបានខ្មែរក្រហមយកទៅសម្លាប់អស់ គឺនៅទួលខាងជើងវត្តជីផុចសព្វថ្ងៃ កន្លែងវិទ្យាល័យមេសាង ឃុំជីផុច ស្រុកមេសាង ខេត្តព្រៃវែង។ នេះបើតាមការបញ្ជាក់របស់អ្នកភូមិ។”

[០៩:៤១:៣៨]

ខ្ញុំនៅសល់ព័ត៌មានរបស់ដើមបណ្ដឹងរដ្ឋប្បវេណីពីររូបតែខ្លីទេ គឺដើមបណ្ដឹងរដ្ឋប្បវេណី ភេន សន (ភេទស្រី) ដែលពាក្យសុំតាំងខ្លួនរបស់គាត់មានលេខ E3/6053។ ក្នុង ERN ជាភាសាខ្មែរ 00501100 ដល់ 01, ជាភាសាអង់គ្លេស 01137778 ដល់ 9, ជាភាសាបារាំងមិនមានទេ តែបានស្នើសុំបកប្រែរួចហើយ។ ខ្ញុំសូមដកស្រង់ដូចតទៅ៖

“ខែធ្នូ ឆ្នាំ១៩៧៦ ប្ដីខ្ញុំត្រូវ តាព្រីង, តាវង្ស, ស៊ុន វ៉ាត់ ចោទប្រកាន់ថា ជាខ្សែរយៈវៀតណាម។ ឯប្ដីខ្ញុំគាត់ពុំដឹងអ្វីទាល់តែសោះ ហើយគាត់ក៏ត្រូវបាន តាព្រីង, តាវង្ស, ស៊ុន វ៉ាត់ យកទៅដាក់ប្រមូលផ្ដុំនៅមន្ទីរឃុំស្វាយជ្រំ ស្រុកមេសាង ខេត្តព្រៃវែង។ នៅទីនោះ ប្ដីខ្ញុំត្រូវបានខ្មែរក្រហមប្រើឲ្យធ្វើការយ៉ាង

ធ្ងន់ធ្ងរជាទីបំផុត។ ប្ដីខ្ញុំគាត់ថា គាត់ប្រឹងប្រែងធ្វើការណាស់ ប្រឹងលត់ដំខ្លួនដោយពុំហ៊ានប្រកែក ឬខ្ជិលឡើយ ព្រោះគាត់ចង់ក្លាយជាមនុស្សស្អាតស្អំ ហ៊ានលះបង់ដើម្បីបដិវត្តន៍ ទោះជាយ៉ាងណាក៏នៅតែមិនរួចទោសដែរ។ ខែមករា ឆ្នាំ១៩៧៧ ប្ដីខ្ញុំត្រូវបានខ្មែរក្រហមបញ្ជូនទៅវត្តស្វាយជ្រំ ក្នុងឃុំស្វាយជ្រំ ឃុំស្វាយជ្រំ ស្រុកមេសាង ខេត្តព្រៃវែង ដើម្បីជួបជុំ។ តែតាមពិត ពេលទៅដល់ទីនោះ ប្ដីខ្ញុំត្រូវបានខ្មែរក្រហម(ពុំស្គាល់ឈ្មោះ) ចាប់គាត់វាយសួរចម្លើយយ៉ាងធ្ងន់ធ្ងរជាទីបំផុត និងវាយនឹងគល់ឫស្សី ជួនវាយនឹងខ្សែតី សួរចម្លើយពេលយប់ ដោយមិនឲ្យស្រែកឡើយ កាលណាស្រែកត្រូវវាយបន្ថែម។ ហើយខ្មែរក្រហមសួរប្ដីខ្ញុំថា តើឯងពិតជាភ្នាក់ងារយួនមែនឬ? ពេលសួរអីត្រូវឆ្លើយហ្នឹង កុំបង្វែរសំណួរឲ្យសោះ។ ដោយទ្រាំនឹងគល់ឫស្សី ខ្សែតី ពុំបានគាត់ក៏ឆ្លើយផ្ដេសផ្ដាសថា គាត់ពិតជាខ្សែរយៈយួន។ តាមពិតគាត់មិនមែនជាខ្សែរយៈយួនទេ។”

[០៩:៤៥:១២]

ខ្ញុំសូមបញ្ចប់ការអានដើមបណ្ដឹងរដ្ឋប្បវេណីម្នាក់នេះ ហើយនិងឈានចូលដល់ដើមបណ្ដឹងរដ្ឋប្បវេណីចុងក្រោយ ដែលដើមបណ្ដឹងរដ្ឋប្បវេណីនោះ គឺលោកស្រី គង់ វុន ដែលមានលេខឯកសារ E3/5937a នេះជាឯកសារបន្ថែមរបស់គាត់។ ហើយសម្រង់ដែលខ្ញុំស្រង់ គឺជាភាសាខ្មែរ 00585239, ជាភាសាអង់គ្លេស 01137902 ដល់ 03, ភាសាបារាំងមិនមានទេ ក៏ប៉ុន្តែបានស្នើសុំការបកប្រែហើយ។ ខ្ញុំសូមអានដូចតទៅ៖ “នៅពេលដែលខ្មែរក្រហមជម្លៀសពួកគាត់ចេញពីកោះគោ (ខ្ញុំសូមបញ្ជាក់ថាជាភាសាអង់គ្លេសសរសេរថាពោះគោ តាមការពិតជាភាសាខ្មែរសរសេរជាកោះគោទេ។ ដូច្នេះភាសាអង់គ្លេសគួរតែបកប្រែជាកោះគោដូចគ្នា។ សូមបញ្ជាក់ថាកោះគោនេះ គឺជាភូមិកោះគោដែលឃុំ -- ស្ថិតនៅក្នុងឃុំព្រៃគគីរ ស្រុកចន្ទ្រា ខេត្តស្វាយរៀង) ខ្ញុំសូមបន្តការដកស្រង់ដូចតទៅនេះ៖

“នៅពេលដែលខ្មែរក្រហមជម្លៀសពួកគាត់ចេញពីកោះគោនោះ ខ្មែរក្រហមបានសម្លាប់ប្រជាជនជាបន្តបន្ទាប់។ ជាពិសេស សម្លាប់អ្នកដែលរត់ទៅវៀតណាម ទៅប្រទេសវៀតណាម ពេលខ្មែរក្រហមចាប់បាន។ នៅខែតុលា ឬខែវិច្ឆិកា ឆ្នាំ១៩៧៨ ខ្មែរក្រហមបានបញ្ជូនអ្នកស្វាយរៀងទាំងអស់ទៅខេត្តពោធិ៍សាត់ និងបាត់ដំបងតាមការដើរពីជ្រៃទៅអ្នកលឿង។ រួចជិះកប៉ាល់ពីអ្នកលឿង ទៅច្បារអំពៅភ្នំពេញ។ បន្ទាប់មក ពីភ្នំពេញទៅព្រៃស្វាយតាមរទេះភ្លើង។ រួចមានអ្នកមូលដ្ឋានទៅៗនៅចាមរអា ស្រុកភ្នំក្រវាញ ពោធិ៍សាត់ មកទទួលយកទៅទាំងអស់។ ពេលទៅដល់ទីនោះ គេឲ្យអ្នកស្វាយរៀងទាំងអស់ទៅច្រូតស្រូវរហូតអស់ ទើបទាហានខ្មែរក្រហមចោទពួកគាត់ថា ជាពួកខ្មាំងក្បាលយួនខ្លួនខ្មែរ រួចឲ្យ

ឈរជាជួរចងដៃបណ្ដើរទៅព្រៃ សម្លាប់ចោលតែម្ដង។ គាត់បានឃើញព្រឹត្តិការណ៍ផ្ទាល់ភ្នែក។ ភាគច្រើន ដែលគេយកទៅសម្លាប់ជាមនុស្សប្រុស បន្ទាប់មក គេយកប្រពន្ធ កូន ទៅសម្លាប់ជាបន្តបន្ទាប់។"

[០៩:៤៧:០៥]

ខ្ញុំសូមបញ្ចប់ការអានព័ត៌មានរបស់ដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់ នាពេលនេះ ហើយសហការីរបស់ខ្ញុំស្នើសុំរយៈពេលមួយនាទី។ បាទ សូមលោកប្រធានអនុញ្ញាត។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

លោកប្រធាន ខ្ញុំសុំពេលមួយនាទី សូមលោកប្រធានអនុញ្ញាត ពីព្រោះថាខ្ញុំភ្លេចជម្រាបជូនអង្គជំនុំជម្រះ និងភាគីអំពីព័ត៌មានសំខាន់មួយ។ ខ្ញុំចង់ជម្រាបជូនថា ខ្លឹមសារនៃឯកសារទាំងអស់ដែលយើងបានបង្ហាញនេះ ពីម្សិលមិញ ហើយនិងថ្ងៃនេះ គឺជាខ្លឹមសារនៃពាក្យសុំដើមបណ្ដឹងរដ្ឋប្បវេណី ហើយនិងព័ត៌មានបន្ថែមរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវបានផ្ទៀងផ្ទាត់អស់ហើយជាមុនពេលចាប់ផ្ដើមសវនាការនេះ គឺផ្ទៀងផ្ទាត់ដោយមេធាវីដែលបានជួបកូនក្ដីរបស់ខ្លួន។ ជួនដោយបុគ្គលិកនៅផ្នែកការងារយើង គឺយើងផ្ទៀងផ្ទាត់ពីខ្លឹមសារនៃចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់ដែលមិនទាន់ស្លាប់ លោកប្រធាន។

ខ្ញុំសូមអរគុណ ដែលលោកប្រធានអនុញ្ញាតឲ្យខ្ញុំពន្យល់ពីខ្លឹមសារជាក់លាក់នេះ ថាយើងបានផ្ទៀងផ្ទាត់ខ្លឹមសារអស់ហើយ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ តទៅនេះផ្ដល់វេទិកាជូនទៅសហ -- តំណាងសហព្រះរាជអាជ្ញា ដើម្បីធ្វើការដាក់បង្ហាញឯកសារគន្លឹះរបស់ខ្លួនចុងក្រោយ ពាក់ព័ន្ធនឹងបីអង្គហេតុ ការប្រព្រឹត្តចំពោះគោលដៅជាក់លាក់។

[០៩:៤៨:៥៣]

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រម ដែលអនុញ្ញាតឲ្យខ្ញុំបង្ហាញនូវក្រុមគោលដៅចុងក្រោយ។ ឯកសារនេះ មានបីប្រភេទដែលត្រូវលើកយកមកបង្ហាញ។ ទី១ នេះជាបទបង្ហាញដែលត្រូវបង្ហាញជូនអង្គជំនុំជម្រះនូវសំអាងរបស់យើងខ្ញុំក្នុងរយៈពេលពីរខែ ឬក៏បីខែក្រោយថ្ងៃ១៧ មេសា ១៩៧៥ ដែលថាគោលនយោបាយនេះ គឺមិនឲ្យប៉ះពាល់ទៅដល់ទាហានលន់នល់ដែលមានបុណ្យស័ក្ដិជាក់លាក់មួយចំនួន។

ឥឡូវនេះ ខ្ញុំសូមចាប់ផ្ដើមរយៈពេលពីមេសា ឧសភា ១៩៧៥ ដែលជារយៈពេលដ៏សំខាន់បំផុត ហើយក៏មានឯកសារដែលបញ្ជាក់អំពីគោលនយោបាយនៅក្នុងខែមេសា ឧសភា ៧៥ ទាក់ -- ពាក់ព័ន្ធនឹងមន្ត្រីទាហានលន់ នល់ កូនទាហានក៏ដូចជានាយទាហានលន់ នល់។ ហើយអ្នកទាំងនោះ ត្រូវបានគេប្រមូល និងយកទៅសម្លាប់ចោល។ ខ្ញុំយល់ឃើញថា ដោយសារតែមានបញ្ជាពីថ្នាក់លើ។

ខ្ញុំសូមបង្ហាញភស្តុតាងពាក់ព័ន្ធទៅនឹងការប្រមូលកូនទាហាន និង នាយទាហានលន់ នល់ នៅថ្ងៃទី១៧ មេសា ៧៥ នៅភ្នំពេញ។ ភស្តុតាងបង្ហាញថា ការប្រមូលផ្ដុំនេះ គឺធ្វើឡើងដោយចេតនា និងរៀបចំយ៉ាងត្រឹមត្រូវ។ ចន ស្វេន គាត់ជាអ្នកសរសេរព្រឹត្តិបត្រ គឺឯកសារ E3/51, ERN អង់គ្លេស S0003728, ខ្មែរ S00644709 ដល់ 710, បារាំង 00597835។ នេះ គឺជាព្រឹត្តិបត្រចេញនៅម៉ោងបួនរសៀល ខែមេសា ៧៥ ដែលរៀបរាប់អំពីព្រឹត្តិការណ៍នៅបរិវេណក្រសួងព័ត៌មាន ដែល ស៊ីដនី ស្ដេនប៊ឺក គាត់បានអញ្ជើញទៅក្រសួងព័ត៌មាននៅរសៀលនោះដែរ។ ហើយនេះជាឯកសារដែលរៀបរាប់ពីព្រឹត្តិការណ៍ដែលបានកើតមានឡើង។ សូមដកស្រង់៖

[០៩:៥១:២៣]

"មានអ្នកទោស៥០នាក់ឈរតម្រង់ជួរនៅមុខអគារ ក្នុងនោះរួមមាន លន់ ណុន ដែលជាប្អូនរបស់សេនាប្រមុខលន់ នល់ មានឧត្តមសេនីយ៍ពីរបីនាក់។ ហ៊ូ ហង្សស៊ិន គឺជានាយខុទ្ទកាល័យរបស់ឡុង បូរ៉េត។ [....] នៅក្រសួងព័ត៌មានបុរសម្នាក់ស្លៀកខោអាវខ្មៅអាយុប្រហែលជា១៥ឆ្នាំ គឺជាមេហើយ។ គាត់បានបែងចែកអ្នកទោសទាំង៥០នេះ ជាបីក្រុម គឺទាហាន អ្នកនយោបាយ និងជនស៊ីវិលធម្មតា។ ខ្មែរក្រហមបានភ្ជង់កាំភ្លើងអ្នកទាំងអស់នោះ គឺថាអ្នកស្លៀកពាក់ខោអាវខ្មៅពាក់ពួក ហ៊ូជីមិញ"។ បញ្ចប់ការដកស្រង់។ ពាក់ពួក ម៉ៅ សេទុង (សូមទោស)។

ហើយតាមរយៈ ស៊ីដនី ស្ដេនប៊ឺក នេះ ដែរ គាត់សរសេរអត្ថបទឯកសារមួយ គឺ E3/3987 ប្រភពនៃឯកសារនេះ គឺចេញមកពីកំណត់ត្រាដោយដៃរបស់គាត់គឺ E336/1/4/3.1 -- គឺ E236/1/4/3.1។ កំណត់ត្រារបស់គាត់នេះ គឺខ្ញុំដកស្រង់ចេញពីប្រភពដើម ដែលត្រូវបានទទួល -- អង្គជំនុំជម្រះទទួលរួចហើយ ដោយអង្គជំនុំជម្រះពេលគាត់មកផ្ដល់សក្ខីកម្ម ប៉ុន្តែខ្ញុំឃើញថា មិនទាន់ E3 ទេពេលនុ៎ង។

ដូច្នេះ អ្នកដែលមានវត្តមានក្នុងពេលគាត់ផ្ដល់សក្ខីកម្ម ដឹងហើយថា អង្គជំនុំជម្រះសាលាដំបូងបានទទួលយកកំណត់ត្រារបស់គាត់ដាក់ចូលក្នុងសំណុំរឿងហើយ។ អ៊ីចឹងសូមបញ្ជាក់ថា ឯកសារនេះ គឺជាឯកសារដែលអង្គជំនុំជម្រះបានទទួលយកហើយៗ មិនមាន E3 ទេ ប៉ុន្តែមាន E។ ហើយឯកសារ

យោងចេញពីកំណត់ត្រានេះ ERN គឺខ្មែរ 00963956 ដល់ 57, អង់គ្លេស 0089827 *(ស៊ីក),* បារាំង 00955419។ ឯកសារនេះ គឺពាក់ព័ន្ធទៅនឹងការប្រមូលផ្តុំមនុស្សនៅក្រសួងព័ត៌មាននៅថ្ងៃ១៧ មេសា ៧៥។ សូមដកស្រង់៖ "មេកងទ័ព គឺថាមិនមានអាយុលើសពី៣៥ឆ្នាំទេ យល់ស្របនិយាយគ្នាជាមួយនឹងអ្នកសារព័ត៌មាន។ នៅពេលដែលមានការបន្តការសុន្ទនានោះ លន់ ណុន បានគេចចេញពីផ្លូវ ហើយ សុំឱ្យអ្នកកាសែតបារាំង សួរទៅមេកងទ័ពនោះថា "តើអ្នកដែលចាត់ទុកថា អ្នកទោសថ្ងៃនេះ អាចចាកចេញពីប្រទេសបានទេ?" ហើយក្រោយមកអ្នកកាសែតនោះ គាត់បានចេញទៅសួរ។ មេកងទ័ពនេះសើចញញឹម។ គឺអាស្រ័យទៅលើរដ្ឋាភិបាលគេជាអ្នកដាក់បញ្ហា។ គាត់និយាយថាគាត់គ្រាន់តែជាមេកងទ័ព គឺមេដឹកនាំនយោបាយ និងមេដឹកនាំប្រទេសមិននៅឆ្ងាយពីទីក្រុងភ្នំពេញទេ គឺថា គេជាអ្នករៀបចំនូវកិច្ចការទាំងអស់នេះ"។ បញ្ចប់ការដកស្រង់។

[០៩:៥៥:០៩]

លោក លោកស្រីចៅក្រម ខ្ញុំលើកឡើងនូវឯកសារយោងសង្ខេបទេ ព្រោះមានភស្តុតាងបញ្ជាក់ថា មាននូវអ្វីកើតឡើងនៅស្ថានទូតបារាំង។ ភស្តុតាងបង្ហាញថា ខ្មែរក្រហមមានគោលដៅនឹងស្វែងរកចាប់ខ្លួនមន្ត្រី ដែលសុំសិទ្ធិជ្រកកោននៅក្នុងស្ថានទូតបារាំង គឺឯកសារ E3.6.94 ដែលបង្ហាញអំពីមន្ត្រីនេះគឺ ឯកសារ E327/100 ជាសារទូរលេខពី ហ្សង់ ស៊ីរ៉ាក់ ជាឯកអគ្គរដ្ឋទូតបារាំងនៅ ២០ មេសា ១៩៧៥ ដែលអនុញ្ញាតឱ្យគេយកមនុស្សទាំងអស់នេះចេញពីស្ថានទូត។ មានកំណត់ត្រាជាក់លាក់មួយទៀតនៅក្នុងសារទូរលេខនេះគឺ ឯកសារ E327/100។ "តាមរយៈអន្តរាគមន៍របស់ខ្ញុំព្រឹកមិញនេះ គណៈកម្មាធិការក្រុង គឺសំដៅទៅលើខ្មែរក្រហមហើយ អនុញ្ញាតឱ្យប្រជាជនកម្ពុជាដែលជ្រកកោននៅស្ថានទូតបារាំងចាកចេញដោយសេរី ដោយមានករណីលើកលែងតែមន្ត្រីជាន់ខ្ពស់មួយចំនួននៅក្នុងក្រុមតែហ្វូងមនុស្សតែប៉ុណ្ណោះ"។ បញ្ចប់ការដកស្រង់។

លោក លោកស្រី គឺថា ក្រោយមកក៏មានការសម្លាប់អ្នកទាំងនោះ គឺឯកសារ E3 ដែរប៉ុន្តែខ្ញុំមិនគ្រប់ដណ្តប់ទៅលើប្រធានបទនេះទេ។

ដោយសារហេតុផលនេះជាហេតុផលមួយថាតើ តាម៉ុក មានការបង្គាប់បញ្ជាខុសពីនេះដែរឬក៏អត់ បើប្រៀបធៀបទៅនឹងភូមិភាគទៀតនោះ។ នេះគឺឯកសារ E319/23.3.42 អង្គជំនុំជម្រះបានទទួលយកឯកសារនេះរួចហើយ គឺទទួលយកនៅពេលដែលសួរសក្ខីកម្មរបស់ សៅ វ៉ាន់។ នេះគឺចម្លើយពីសាក្សីម្នាក់ដែលជាមេបញ្ជាការកងវរសេនាតូចពិសេសមួយ នៅត្រង់ចម្លើយ២៩ ដល់ ៣៧ គាត់បាន

រៀបរាប់ថា គាត់នៅឯអាកាសយានដ្ឋានពោធិ៍ចិនតុង នៅ១៧ មេសា ១៩៧៥ នៅជាមួយ តាម៉ុក។ គឺនៅថ្ងៃ១៧ មេសា ៧៥ គឺត្រង់ចម្លើយលេខ៣០ សូមដកស្រង់៖ "នៅម៉ោងប្រហែលប្រាំបួនព្រឹក តាម៉ុក, ស៊ូ ម៉េត និង មាស មុត បានមកដល់ព្រលានយន្តហោះពោធិ៍ចិនតុង។ តាម៉ុក បានបញ្ជាទាហានលន់ នល់ ទាំងអស់និងអាកាសយានិកទាំងអស់ឲ្យឡើងជិះឡានទ្រង់ធំមួយ។ ពួកគេបានដឹកជញ្ជូនអ្នកទាំងនោះឆ្ពោះទៅទិសខាងលិច ដោយបានប្រាប់ថា ឲ្យទៅទទួលអង្គការ"។ បញ្ចប់ការដកស្រង់។

[០៩:៥៨:៣៥]

សាក្សីបន្តផ្តល់សក្ខីកម្មទៀតថា "ទាហានលន់ នល់ និងអាកាសយានិកទាំងនោះត្រូវបានកងវរសេនាតូចពិសេសមួយយកខ្លួនដឹកយកចេញទៅតាមការបញ្ជារបស់ តាម៉ុក។ គឺថាមានម្នាក់ក្នុងមួយឡានៗប្រហែលជា ៣០ ទៅ ៤០នាក់។" ត្រង់ចម្លើយលេខ៣៧ ហើយចម្លើយ៣៤ ដល់ ៣៥ គាត់បានឆ្លើយដូចតទៅ៖ "សួរ៖ តើលោកស្តាប់ឮពីកងទ័ពដែលដឹកជញ្ជូនអ្នកទាំងនោះថាមានអ្វីកើតឡើងទៅអ្នកទាំងនោះទេ? ឆ្លើយ៖ តាម៉ុក ខ្លួនឯងហ្នឹងបាននិយាយថា អ្នកទាំងអស់នេះនឹងត្រូវដឹកយកទៅកម្ទេចចោលតែម្តង។ សួរ៖ តាម៉ុក និយាយថាអ៊ីចឹងនៅពេលណា? ឆ្លើយ៖ តាម៉ុកឆ្លើយក្រោយពីទាហានលន់ នល់ ហ្នឹងគេដឹកជញ្ជូនតាមឡានទៅ។" បញ្ចប់ការដកស្រង់។

មានឯកសារមួយទៀត ដែលនិយាយអំពីអ្វីដែលបានកើតឡើងទៅនឹងកងទ័ពភូមិភាគនិរតីក្រោយ ១៧ មេសា ៧៥។ នេះគឺជាឯកសារចេញពី ហង់រី ឡូកា ដែលសៀវភៅរបស់គាត់សរសេរថា "អ្នកទោសនៃរបបខ្មែរក្រហម" គឺឯកសារ E3/24/19, ERN អង់គ្លេស 00293762 ដល់ 63, មិនមានការបកប្រែនៅសម្រង់នេះនៅឡើយទេ លោកប្រធាន។

[១០:០០:១១]

នេះគឺអ្វីដែល ហង់រី ឡូកា បានសរសេរ សូមដកស្រង់៖ "នៅថ្ងៃ២០មេសា ៧៥ ក្នុងពេលដែលមានការបះបោរយ៉ាងខ្លាំងនៅវាលវេញនោះ គឺមានការប្រមូលផ្តុំទាហាននៅទីនោះ។ ហើយគឺថា អ្នកទាំងអស់នេះ គឺថាចូលមកដោយសារតែវៀតណាមមកលុកលុយទឹកដីនោះ អ្នកខ្លះបានប្រាប់ឈ្មោះរបស់ពួកគេ ទោះបីមិនមែនជាកងទ័ពក៏ដោយ។ ដំបូង ពួកគេត្រូវបានដឹកតាមរយៈឡានធំៗប្រហែលជា ២០គ្រឿង ហើយការដឹកជញ្ជូនទី លើកទី២ មានឡានធំៗហ្នឹង២០ឡានទៀត។ ហើយអ្នកទាំងអស់នោះក៏បានដឹកទៅកាន់ជួរភ្នំបូកគោ នៅជិតកាស៊ីណូ ហើយនៅជោគវាសនារបស់អ្នកទាំងនេះ នៅថ្ងៃទី២០ មេសា ៧៥ នោះ គឺនៅក្នុងរយៈពេលមួយសប្តាហ៍ពេញតែម្តង។ ទាហាន លន់ នល់ រាប់ពាន់នាក់ រួម

ទាំងគ្រួសាររបស់គេ ត្រូវបានសម្លាប់ចោល។ ពួកអ្នកទាំងអស់នេះ គឺគេសម្លាប់ចោលនៅក្បែរនឹងវត្តមួយ។ ស្ត្រីៗហ្នឹង គឺថាមានការ គឺៗគឺឃើញគេសម្លាប់ប្ដីរបស់អ្នកទាំងនោះនឹងភ្នែកតែម្ដង។ ហើយជនរងគ្រោះ គេទម្លាក់ចេញពីជ្រលងភ្នំៗតែម្ដងចុះមកក្រោម។ ហើយអ្នកខ្លះក៏ព្យាយាមរត់គេចខ្លួន ប៉ុន្តែខ្មែរក្រហមដេញតាមចាប់ និងសម្លាប់អ្នកទាំងនោះចោលតែម្ដង។" បញ្ចប់ការដកស្រង់។

មានឯកសារខ្លះទៀត ក៏បង្ហាញថាតើ អ្នកណាជាអ្នកបានបញ្ជាចំពោះការសម្លាប់មន្ត្រីទាហានលន់នល់ និងកូនទាហានលន់នល់ក្នុងអំឡុងពេលនោះផងដែរ។ ទី១ នៅថ្ងៃ ខែឧសភា ៧៥ មានរបាយការណ៍សារព័ត៌មានមួយរៀបរាប់អំពីការទាក់ទងតាមវិទ្យុដែលត្រូវបានគេលបស្ដាប់ គឺការទាក់ទងតាមវិទ្យុដោយមេខ្មែរក្រហម គឺឯកសារ E3/3393 ជាកាសែត *ឡូសអ៊ិនជេលេស ថាមស៍* ដែលរាយការណ៍នៅខែឧសភា ៧៥។ កាសែតនេះ រាយការណ៍អំពីការចេញព័ត៌មានប្រចាំសប្ដាហ៍ថា គេបានលបស្ដាប់វិទ្យុទាក់ទងរបស់ខ្មែរក្រហមស្ដីអំពីការសម្លាប់មន្ត្រីរដ្ឋការ ក៏ដូចជាទាហាននៃរបបសាធារណរដ្ឋខ្មែរ។

[១០:០៣:០៥]

ព័ត៌មាននេះ គឺយើងទទួលបានពីការលបស្ដាប់ការទាក់ទងគ្នារបស់ខ្មែរក្រហម ដោយភ្នាក់ងារអាមេរិក។ អ្នកទាំងអស់នោះ ត្រូវបានគេដឹងថា គឺជាមន្ត្រីទាហាន ក៏ដូចជាមន្ត្រីរដ្ឋការលន់ នល់ ហើយទាហានទាំងអស់ដែលៗ -- បាទ គឺស័ក្ដិ៤ចុះមកហ្នឹង គឺថាត្រូវតែសម្លាប់ចោលតែ -- ថាស័ក្ដិ៥ ឡើងទៅត្រូវតែសម្លាប់ចោលតែម្ដង។

ខ្ញុំសូមប្រាប់នូវអ្វីដែលកងទ័ពខ្មែរក្រហមខ្លួនឯងបានទាក់ទងនឹងគ្នាគេ ហើយនិយាយអំពីបញ្ហានេះ។ ឯកសារ E3/3364 ជាកាសែតវ៉ាស៊ីនតោនប៉ុស្ដិ៍។ ពីរថ្ងៃក្រោយមក គឺនៅថ្ងៃទី០៦ ខែឧសភា ៧៥ ក៏បានបញ្ជាក់ថា សេតវិមានក៏បាន ទទួលបាននូវការលបស្ដាប់ការប្រាស្រ័យទាក់ទងគ្នានេះផងដែរ។ នៅប្រាំមួយថ្ងៃក្រោយមកទៀត នៅថ្ងៃទី១២ ឧសភា ៧៥ កាសែតវ៉ាស៊ីនតោនប៉ុស្ដិ៍ គឺឯកសារ E3/3370 ដែលសរសេរថាៈ "មិនយូរប៉ុន្មានក្រោយពីពួកកុម្មុយនីស្ដបានរឹបអូសបានទីក្រុងភ្នំពេញ និងទូទាំងប្រទេស ពួកគេបានចេញជាសេចក្ដីណែនាំសម្ងាត់ ឱ្យកម្មេចមន្ត្រីជាន់ៗខ្ពស់ ក៏ដូចជានាយទាហានជាន់ខ្ពស់ទាំងអស់។ ហើយក៏ដូចជាមន្ត្រីសាលាខេត្តទាំងអស់ដែល គឺថាប្រឈមមុខជាមួយលន់នល់ហ្នឹងក៏ត្រូវតែប្រមូលយកទៅសម្លាប់ចោល។ នេះគឺការប្រាស្រ័យទាក់ទង ដែលខាងភ្នាក់ងារសម្ងាត់របស់អាមេរិកបានលបស្ដាប់ ហើយផ្ញើព័ត៌មាននេះទៅឱ្យក្រសួងការបរទេស។ (យើងបានទទួលអត្ថបទនេះមួយច្បាប់ផងដែរ) វិទ្យុទាក់ទងនៅតាមមូលដ្ឋានមួយទៀត ក៏បញ្ជាក់អំពីការចាប់ផ្ដើមសម្លាប់បង្ហូរ

ឈាមនោះផង ដែរ។ អង្គភាពមួយដែលដឹកនាំដោយ -- បានអំពាវនាវឲ្យសម្លាប់នាយទាហាន គឺថាចាប់ពីស័ក្តិ១ ហ្នឹងរហូតទៅដល់ស័ក្តិ៥ ស្លាប់ចោលឲ្យអស់ សម្លាប់ទាំងប្រពន្ធនិងកូនផង”។ បញ្ចប់ការដកស្រង់។

[១០:០៥:៤០]

មានភស្តុតាងបញ្ជាក់គាំទ្រទៅដល់ឯកសារនេះផងដែរ គឺឯកសារ E3/89 ការសម្ភាស អៀង សារី ដោយ ស្ទីវ ហេដឌ័រ ERN ជាភាសាខ្មែរ 00062461, អង់គ្លេស 00417606, បារាំង 00332688។ ក្នុងការឆ្លើយតបទៅនឹងសំណួរដែលពាក់ព័ន្ធទៅនឹងសេចក្តីសម្រេចរបស់ថ្នាក់លើឲ្យសម្លាប់មនុស្សបន្ថែមទៅលើពួកមហាក្បត់ទាំងប្រាំពីរនាក់។ សូមដកស្រង់សម្តីរបស់ អៀង សារី៖ “សេចក្តីសម្រេចនេះ គឺថាត្រូវបានសម្រេចក្រោយថ្ងៃ ១៧មេសា ៧៥ ប្រហែលជាក្នុងថ្ងៃ២០ មេសានេះ តាមដែលខ្ញុំដឹង។ មានន័យថា ពួកគេថាត្រូវចាត់វិធានការយ៉ាងណាក៏ដោយ ការពារធ្វើម៉េចកុំឲ្យអ្នកទាំងអស់នោះ ងើបឡើងបះបោរប្រឆាំងទៅនឹងបដិវត្តន៍”។ បញ្ចប់ការដកស្រង់។

កិច្ចសម្ភាសន៍របស់ ស្ទីវ មួយទៀត គាត់សម្ភាសលោក អ៊ុក ប៊ុនឈឿន ឯកសារ E3/387 – E3/387, ខ្មែរ 00379486, អង់គ្លេស 00350205, បារាំង 00441418។ សូមដកស្រង់៖ “នៅខែមេសា ៧៥ ប៉ុល ពត បានចេញគោលនយោបាយសម្ងាត់មួយទៀត គឺត្រូវបោសសម្អាតសមាសធាតុទាំងអស់ពីរបបលន់ នល់។ ទាក់ទងទៅនឹងជនស៊ីវិល និងរដ្ឋបាលមូលដ្ឋាន គឺថា ពីមេឃុំឡើងទៅគឺត្រូវតែបោសសម្អាត ហើយទាហានវិញ គឺថាពីស័ក្តិ១ ទៅដល់ឧត្តមសេនីយ៍ហ្នឹង គឺថាត្រូវតែប្រមូលបោសសម្អាត”។ ហើយកិច្ចសម្ភាសន៍លើកទី៣ គឺសម្ភាស ម៉ាត់ លី ដែលយើងខ្ញុំបានលើកឡើងពីម្សិលរួចមកហើយ គឺឯក -- E3/390, ERN អង់គ្លេស 00436867 ដល់ 868, ខ្មែរ 00392094 ដល់ 95, បារាំង 00479807 ដល់ 08។ សូមដកស្រង់៖ “គោលនយោបាយក្នុងស្រុក ចាប់ផ្តើមចេញពីចំណុចនេះ គឺចាំបាច់ណាស់ដែលត្រូវជីកស្មៅត្រូវជីកទាំងឫស គឺពួកអ្នកទីក្រុងនេះឯង ហើយបើរកឃើញថា អ្នកណាស័ក្តិ១ ស័ក្តិ២ គឺថា សម្លាប់អ្នកទាំងនោះចោល។ ដើម្បីសម្លាប់ចោលអ្នកទាំងនោះចោលបានគេធ្វើដោយរបៀបដូចតទៅ -- គេៗត្រូវល្បួងអ្នកទាំងនោះ”។ សូមបញ្ចប់ការដកស្រង់។

[១០:០៩:០២]

លោក លោកស្រីចៅក្រម ប្រភេទឯកសារទី២ ដែលជាឯកសារយោងនេះ គឺជាភស្តុតាងទាក់ទងទៅនឹងតំបន់១៣ នៃភូមិភាគនិរតី។ សៅ វ៉ាន់ បានបង្ហាញភស្តុតាងថា មានការបញ្ជាចេញពី

តំបន់១៣ -- ពីលេខាតំបន់១៣។ នេះគឺជាឯកសារបញ្ជាក់ថា អំពីអ្វីដែលបានបន្តកើតមានឡើងតទៅទៀតនៅក្នុងតំបន់នេះតែម្តង។ ទី១ ខ្ញុំសូមនិយាយអំពី សៅ វ៉ាន់ តែម្តង ដែលមកពីស្រុកត្រាំកក់ បន្ថែមទៅលើភស្តុតាងដែលអង្គជំនុំជម្រះបានស្តាប់រួចមកហើយ នូវអ្វីដែលបានកើតមានឡើងនៅវត្តចំប៉ា។

សម្រង់មួយចេញពី អ៊ា ម៉េងទ្រី និយាយអំពីខ្សែចង្វាក់នៃភាពភ័យខ្លាច គឺឯកសារ E3/2120 ហើយក៏មានឯកសារ E3/2121 នោះផងដែរ។

មានឯកសារពីរផ្សេងគ្នា ដែលមានលេខ E3 ដោយសារការបកប្រែមានការបកប្រែពាក់ព័ន្ធទៅនឹងសៀវភៅទី២ ប៉ុន្តែសៀវភៅទី១ មិនមានការបកប្រែពាក់ព័ន្ធទៅនឹងសៀវភៅនេះទេ។ ម៉េងទ្រី បានសរសេរនៅពេញមួយជំពូកតែម្តង ស្តីអំពីការចាប់ខ្លួន ដែលភាគច្រើននៃអ្នកដែលត្រូវគេចាប់ខ្លួនហ្នឹង គឺនៅពាក់កណ្តាលឆ្នាំ៧៥ ឬក៏៧៦នោះ គឺជាទាហានលន់ នល់ ឬក៏ជាប៉ូលិសរបបលន់ នល់។ ខ្ញុំសូមចាប់ផ្តើមត្រង់ ERN អង់គ្លេស 00416383, ខ្មែរ 0109874 មិនមានការបកប្រែជាភាសាបារាំងនៅឡើយទេ។ អ៊ា ម៉េងទ្រី សរសេរដូចតទៅ៖ "កម្មាភិបាលម្នាក់ឈ្មោះ តេង មកពីឃុំពពេល ជាឃុំមួយចំណុះឲ្យស្រុកត្រាំកក់ អតីតមេឃុំពពេល ឈ្មោះ តេង នេះ និយាយថា -- សូមទោស គឺ តេង កម្មាភិបាលពពេលហ្នឹង ថាមេឃុំហ្នឹង គឺបានចាប់ផ្តើមឲ្យប្រមូលមនុស្សនៅក្នុងឃុំពពេល។ គាត់និយាយថា មានការប្រមូលប្រវត្តិរូប កម្មាភិបាលបានទទួលព័ត៌មានលម្អិតអំពីឈ្មោះ តួនាទី ប្រពន្ធកូន និងមុខងាររបស់ពួកគេ។ ក្រោយពីប្រមូលប្រវត្តិរូបអ្នកទាំងអស់នោះហើយ ឆន បានបញ្ជូនរបាយការណ៍ទៅគណៈកម្មាធិការស្រុក ហើយអ្នកនៅឃុំពពេល ដែលជានគរបាល និងជាទាហាន គឺថាត្រូវបានបាត់ខ្លួនជាបន្តបន្ទាប់។" បញ្ចប់ការដកស្រង់។

ឯកសារយោងទៅលើឈ្មោះ ឆន នោះ គឺគាត់ជាមេឃុំពពេល ហើយជាប្តីរបស់ យាយ ធឿន ដែលបានមកផ្តល់សក្ខីកម្មហើយ។ យាយធឿន ដែលបានមកផ្តល់សក្ខីកម្ម គាត់រៀបរាប់ដំណើររឿងដូចគ្នានេះដែរ។

[១០:១២:១៧]

ឯកសារទី២ មកពីត្រាំកក់ គឺកំណត់ហេតុស្តាប់ចម្លើយ ឈ្មោះ អៀប ឌុច ជាអតីតប្រធានយុវជនស្រុក ហើយក្រោយមក ធ្វើការនៅសន្តិសុខក្រាំងតាចាន់ គឺឯកសារ E3/4627, អង់គ្លេស 006230677, ខ្មែរ 00163493, បារាំង 00651 ដល់52 -- បាទ បារាំង 00651259 ដល់60។

"សួរ៖ តើពួក១៧មេសា ត្រូវបានឃ្លុបប្រមូលផ្តុំ ហើយបញ្ជូនទៅក្រាំងតាចាន់ មែនទេ? ឆ្លើយ៖

ខ្ញុំមិនដឹងថា ថ្នាក់ជាសម្រេចទៅលើផែនការនេះនោះទេ។ នៅពេលពួកគេមកដល់ទីនេះ គេបានប្រមូលប្រវត្តិរូបអ្នកទាំងអស់នោះ ហើយអ្នកណាសរសេប្រវត្តិរូបថាខ្លួនធ្លាប់ធ្វើជាទាហានហ្នឹង បាត់ខ្លួនហើយ ហើយអ្នកដទៃទៀត គឺថាគេទុកនៅមូលដ្ឋាន ប៉ុន្តែពួកគេនេះ គឺថ្នាក់លើជាអ្នកសម្រេច។ ថ្នាក់លើដែលខ្ញុំនិយាយនេះ គឺខ្ញុំនិយាយអំពីទូទាំងប្រទេសតែម្តង គឺថ្នាក់លើហ្នឹង គឺខ្ញុំសំដៅទៅលើមជ្ឈិមតែម្តង។" បញ្ចប់ការដកស្រង់។

លោក លោកស្រី មានភស្តុតាងចេញមកពីមនុស្សពីរនាក់ មកពីស្រុកនោះ មកពីតំបន់១៣ដែរ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ។ ឥឡូវនេះ ដល់ពេលសមស្របសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងដប់កន្លះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១៤ នាទី ដល់ម៉ោង ១០:៣២ នាទី)*

[១០:៣១:៥៤]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញារងអន្តរជាតិដើម្បីបន្តការដាក់បង្ហាញឯកសារគន្លឹះរបស់ខ្លួន។

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំកំពុងតែបង្ហាញប្រភេទឯកសារក្រុមទី២ គឺជាឯកសារភស្តុតាងទាក់ទងទៅនឹងតំបន់១៣ ភូមិភាគនិរតីដែលបង្ហាញថា មុនឬក៏ម្តុំពេលជាមួយគ្នា ដែលមានការប្រជុំមួយដែល សៅ វ៉ាន់ បានលើកឡើងថា មានការសម្លាប់មន្ត្រីរបបលន់ នល់។ ឥឡូវនេះ ខ្ញុំសូមចូលទៅស្រុក

អង្គរជ័យ ជាស្រុកមួយទៀតចំណុះឲ្យតំបន់១៣ដែរ ក៏មានការលើកឡើងថា មានការប្រជុំនៅស្រុកអង្គរជ័យនេះ គឺឯកសារ E319/19.3.125 ជាចម្លើយរបស់បុគ្គលម្នាក់ដែលជាសមាជិកគណៈកម្មាធិការឃុំនៅក្នុងស្រុកអង្គរជ័យចំណុះឲ្យតំបន់១៣។ ពីចម្លើយលេខ១០ ដល់ ១៧ គាត់បានរៀបរាប់ថា មួយសប្តាហ៍ ឬពីរសប្តាហ៍ក្រោយរបបលន់នល់ដួលរំលំទៅ និងអនុលោមទៅតាមបញ្ជារបស់ថ្នាក់លើ គឺទាហាន និងមន្ត្រីរដ្ឋការលន់ នល់ ចាប់ផ្តើមពីស័ក្តិ១ឡើងទៅ ត្រូវបានគេហៅឲ្យទៅចូលរួមប្រជុំ ហើយគេយកទៅសម្លាប់ចោល។ ស្រុកមួយទៀតនៅក្នុងតំបន់១៣ ស្រុកគិរីវង់ គឺឯកសារ E3.3.2.0 -- E3/3.3.2.0 និយាយអំពីទាហាននៃរបប លន់ នល់ នោះផងដែរ នៅត្រង់ចម្លើយលេខ១៥ ដល់ ២៥ និងចម្លើយលេខ៣៧ ដល់៤៤ នៃកំណត់ហេតុស្តាប់ចម្លើយរបស់គាត់។ គាត់បានរៀបរាប់ថា គាត់នៅក្នុងក្រុមចំណោម ទាហានលន់ នល់ ១៨០នាក់ ហើយក៏មានមេ៥០ខ្នងផងដែរ ដែលនៅក្នុងខែតុលា ៧៥ នោះ ត្រូវបានគេប្រមូលដាក់ក្នុងវត្តមួយ នៅស្រុកគិរីវង់ គឺយាយបូ ជាអ្នកប្រមូល។ យាយ បូ នៅពេលនោះ គឺជាសមាជិកគណៈកម្មាធិការស្រុកគិរីវង់។ គាត់បានរៀបរាប់ថា តើទាហានលន់ នល់ មួយក្រុមដែលមានគ្នា១៨០នាក់ហ្នឹង គឺត្រូវបានគេនាំចូលទៅក្នុងព្រៃ និងសម្លាប់ចោល ប៉ុន្តែគាត់វិញ គឺសំណាងល្អ បានរត់គេចខ្លួន រស់រានមានជីវិត។ យាយបូ គឺជាប្អូនរបស់ យាយប៊ុន -- យាយ បឿន ហើយក្រោយមក ក្លាយទៅជាលេខាស្រុក នៅស្រុកកៀនស្វាយ បន្ទាប់ពី សៅ វ៉ាន់ ដែលគេបញ្ជូនមកពីស្រុកត្រាំកក់មក។

[១០:៣៦:០៤]

នៅស្រុកគិរីវង់នេះផងដែរ គឺឯកសារ E3/9598 ឯកសារ E3/9598 ចម្លើយលេខ១៤ ដល់ ១៥។ សាក្សីរូបនេះ បានរៀបរាប់អំពីអង្គប្រជុំដែលអធិបតីភាពដោយលេខាស្រុកគិរីវង់ គឺតាទិត្យ ដែលជាប្អូនថ្លៃរបស់ តាម៉ុក។ នេះគឺជាកិច្ចប្រជុំនៅចុងឆ្នាំ១៩៧៦ ឬដើមឆ្នាំ៧៧ ត្រង់ចម្លើយលេខ១៤-១៥ គាត់បានឆ្លើយ សូមដកស្រង់៖ “ខ្ញុំបានចូលរួមក្នុងអង្គប្រជុំមួយដែលដឹកនាំដោយ តាទិត្យ នៅវត្តព្រៃរំដេង។ តាទិត្យ បានប្រកាសថា យើងត្រូវប្រមូលពួកទាហានលន់ នល់ ដែលជាពួកក្បត់។ នៅក្នុងកិច្ចប្រជុំនោះ គេបានចងដៃរបស់គាត់ ហើយឲ្យទាហានលន់ នល់ ម្នាក់ហ្នឹង ទៅបង្ហាញអត្តសញ្ញាណអ្នកដទៃទៀត។ ខ្ញុំមិនដែលឃើញ ហ៊ុយ ស៊ីម ម្តងទៀតទេ។ ហ៊ុយ ស៊ីម ប្រហែលជាគេយកទៅសម្លាប់ចោលហើយ។ តាទិត្យ បានប្រកាសថា ហ៊ុយ ស៊ីម គឺជាខ្មាំងរបស់អង្គការ។” ហើយមានឯកសារយោងមួយចំនួនទៀត ចេញមកពីស្រុកដទៃទៀត ដែលជាស្រុកចំណុះឲ្យភូមិភាគនិរតីផងដែរ គឺស្រុក

បាទី នៅចំណុះឲ្យតំបន់៣៣ ភូមិភាគនិរតី។ ខ្ញុំដកស្រង់ចេញពីសៀវភៅរបស់ អ៊ា ម៉េងទ្រី គឺ E3/2120 និងឯកសារ E3/2121។

អ៊ា ម៉េងទ្រី សរសេរសៀវភៅមួយរៀបរាប់អំពីមន្ទីរសន្តិសុខនៅភូមិភាគនិរតី។ ERN អង់គ្លេស 00416382, ខ្មែរ 01098793 មិនមានការបកប្រែជាភាសាបារាំងនៅឡើយទេ។ ម៉េងទ្រី បានសរសេរដូចតទៅ អំពីស្រុកបាទី សូមដកស្រង់៖ “ជឹម ដែលជាលេខាស្រុកបាទី ពីឆ្នាំ១៩៧០ ដល់៧៥ នោះ បានឃើញបញ្ជីឈ្មោះមនុស្ស។ គាត់បានពន្យល់ថា អ្នកដែលស្ថិតនៅក្នុងបញ្ជីនោះ គឺត្រូវគេរៀបរាប់សរសេរឈ្មោះ និងតួនាទីរបស់អ្នកទាំងអស់នោះ។ គាត់ថានៅដើមឆ្នាំ១៩៧៦ មានទាហានលន់ នល់ និងនគរបាលលន់ នល់ ច្រើនជាងប្រភេទមនុស្សដទៃទៀត។” បញ្ចប់ការដកស្រង់។

[១០:៣៨:៤០]

នៅERN ទំព័រដដែល ម៉េងទ្រី ក៏បានសរសេរអំពីស្រុកព្រៃកប្បាស នៅក្នុងតំបន់៣៣នៃភូមិភាគនិរតីផងដែរ។ សូមដកស្រង់៖ “នៅពាក់កណ្តាលឆ្នាំ៧៥ ទុយ ដែលជាប្រធានស្រុកកំពង់សៀមបានទទួលផែនការរបស់បក្សដើម្បីរែកមុខ និងរកមុខទាហានលន់ នល់ និងបញ្ជូនទៅថ្នាក់លើ។ ក្រោយពីទទួលបានប្រវត្តិរូបផ្ទាល់ខ្លួនមក ទុយ ក៏បានបញ្ជូនរបាយការណ៍នេះទៅស្រុក គណៈកម្មាធិការស្រុកព្រៃកប្បាស។” ហើយខ្ញុំសូមរំឭកដល់អង្គជំនុំជម្រះផងដែរថា ចៅហ្វាយស្រុកព្រៃកប្បាសនេះ គឺឈ្មោះ ចុង ជាប្អូនរបស់តាម៉ុក។ ឯកសារមួយទៀត គឺស្រុកកៀនស្វាយ គឺជាស្រុកមួយដែល សៅ វ៉ាន់ ហើយនិង យាយបូ ដែលខ្ញុំលើកពីខាងដើមនេះ ត្រូវបានចាត់តាំងនៅក្នុងឆ្នាំ៧៦ ឲ្យទៅធ្វើការនៅទីនោះ។

[១០:៣៩:៤៨]

ឯកសារ E3/4659 – E3/4659 គឺជាកិច្ចសម្ភាសន៍អ្នកមូលដ្ឋានម្នាក់មកពីស្រុកកៀនស្វាយ ហើយនេះ គឺជាអ្វីដែលសាក្សីរូបនេះបានឆ្លើយថា មានអ្វីកើតឡើងក្រោយពីកម្មាភិបាលនិរតីបានទៅដល់ស្រុកកៀនស្វាយនោះ។ សូមដកស្រង់៖ “កម្មាភិបាលភូមិភាគនិរតីជំនួសកម្មាភិបាលភូមិភាគបូព៌ា។ ភូមិភាគបូព៌ាជាអ្នករំដោះតំបន់នេះ គឺទ័ពរបស់ ចាន់ ចក្រី ដែលក្រោយមកត្រូវបានគេចាប់ខ្លួន គឺថាតែងតែមកពិនិត្យនៅកន្លែងនោះ។ គាត់ធាត់ ទាប ជាអ្នកពូកែនិយាយ។ បើគាត់ចង្អុលចំឈ្មោះអ្នកណាហើយ អ្នកនោះស្លាប់ហើយ។ មន្ទីរសន្តិសុខនុ៎ងត្រូវបានបង្កើតឡើងនៅពេលដែល បូ និង ថ្លាង បានមកដល់ទីនោះ។ អ្នកទាំងនេះ គឺថាជាប្រធានមន្ទីរសន្តិសុខនៅទីនោះ។ កម្មាភិបាលនិរតីហ្នឹង បានមករែកមុខរកគ្រូបង្រៀន និងអ្នកដទៃទៀត។ ប្រធានកង ក៏ដូចសហករណ៍ ត្រូវធ្វើរបាយការណ៍ទៅ ថ្លាង ហើយអ្នក

ទាំងអស់នោះក្រោយមកត្រូវគេចាប់ខ្លួន។ ប្អូនថ្លៃរបស់ខ្ញុំ នូ យ៉ាន ហើយនិងមនុស្ស៥០នាក់ជាងទៀត គឺត្រូវគេប្រមូលនៅឃុំឫស្សីស្រុក។ គាត់ធ្វើការកប៉ុកកំប៉ុកទេ នៅក្នុងមុខងារសាធារណៈ ហើយគេថាគាត់ហ្នឹងស័ក្តិ៤។

ហើយក៏មានចម្លើយពីមជ្ឈមណ្ឌលឯកសារកម្ពុជា គឺ E356/37 ដែលឆ្លើយបញ្ជាក់ដោយសាក្សីម្នាក់មកពីស្រុកកៀនស្វាយ ដែលរៀបរាប់អំពីព្រឹត្តិការណ៍ពាក់ព័ន្ធទៅនឹងការចាប់ខ្លួនអ្នកទោសថា ពាក់ស័ក្តិ១។ បើខ្ញុំសរុបជាមួយនឹងឯកសារប្រភេទទី១ ខ្ញុំសូម -- នូវឯកសារប្រភេទទី៣ គឺជាឯកសារភស្តុតាង បញ្ជាក់អំពីការចាប់ខ្លួន និងការសម្លាប់មន្ត្រីរដ្ឋការរបប លន់ នល់ ដែលបន្តៗមានចាប់តាំងពីខែឧសភា ៧៥ គឺក្រោយពីមានការបញ្ជាក់ថាមានអង្គប្រជុំមួយ។ ដូច្នេះ មានឯកសារបីប្រភេទ ឯកសារ E3832 ជាឯកសារដែលចុះថ្ងៃទី០៤ ឧសភា ៧៥ បញ្ជាក់ថា មានពួកក្បត់១៧នាក់ ដែលបក្សបានពិនិត្យ និងសម្រេចថាត្រូវកម្ទេចចោល។

[១០:៤២:៤៦]

នេះ គឺមកពី *កាំវ៉ាដ* ពីន គឺជាកម្មាភិបាលមកពីកងពលលេខ៧០៣ ហើយឯកសារបញ្ជាក់ថាមនុស្សទាំងអស់នោះ គឺជាអ្នកណាខ្លះនៅក្នុងចំណោមពួកក្បត់ទាំង១៧ នៅបញ្ជីនេះ ដែលបក្សសម្រេចឲ្យសម្លាប់នៅខែឧសភា ៧៥នោះ -- មិថុនា ៧៥ គឺមានស័ក្តិ៥ម្នាក់ ស័ក្តិ៤ម្នាក់ ស័ក្តិ១ម្នាក់ ស័ក្តិ២បីនាក់ និងស័ក្តិ១ម្នាក់។ អ្នកទាំងអស់នេះ គឺមានឋានន្តរសក្តិពីស័ក្តិ១ ទៅដល់ស័ក្តិ៥។ នេះ គឺៗដែល សៅ វ៉ាន់ បាននិយាយថា មិនត្រូវប៉ះពាល់នោះ។

កំណត់ត្រាពីស-២១ ផងដែរនោះ គឺឯកសារ E3/1539 ជាបញ្ជីទាហានលន់ នល់ ១៦២នាក់ រួមទាំងគ្រួសាររបស់ពួកគេផងដែរ ដែលត្រូវបានសម្លាប់ ឬក៏ស្លាប់ដោយសារជំងឺនៅស-២១ ចន្លោះពីថ្ងៃទី២២ ទៅដល់៣១ ខែមីនា ១៩៧៦។ ហើយអ្វីដែលខ្ញុំចង់ធ្វើការកត់សម្គាល់ពិសេសនោះ គឺថាបញ្ជីនេះរួមមានស័ក្តិ៥ បួននាក់, ស័ក្តិបួនកន្លះបួននាក់ -- ប្រាំមួយ -- ស័ក្តិ៣ប្រាំមួយនាក់, ស័ក្តិ១ពីរនាក់ ហើយនិងស័ក្តិ២ ម្នាក់, ស័ក្តិ៤ ១៤នាក់ -- ស័ក្តិ១ ១៤នាក់ គឺទាហានលន់ នល់ ដែលមានឋានន្តរសក្តិទាំងនេះក៏ត្រូវតែបន្តចាប់ខ្លួន និងយកទៅសម្លាប់ចោល ក្រោយពីមានកិច្ចប្រជុំមួយ ដែល សៅ វ៉ាន់ រៀបរាប់ឡើងថា គាត់បានចូលរួមដែរនោះ។

ឯកសារ ស-២១មួយទៀត គឺឯកសារ E3/3973 -- E3/39.73 នេះ គឺជាបញ្ជីអ្នកទោសដែលគេសម្លាប់ ស-២១ ខ្មែរ គឺ0006642 ដល់ 6646, អង់គ្លេស 00837571 -- 581 ដល់ 582, បារាំង

008--

**អ្នកបកប្រែ៖**

លោកប្រធាន សូមការអនុញ្ញាឲ្យសហព្រះរាជអាជ្ញាបន្ថយល្បឿនបន្តិច តាមអត់ទាន់លោកប្រធាន។

**លោក ឌេល លីសាក់៖**

បញ្ជីនេះ គឺមានបញ្ជីអ្នកទោស២០៦នាក់ គឺជាទាហាន លន់ នល់ ដែលត្រូវបានគេឃុំខ្លួននិងសម្លាប់នៅស-២១ ឯកសារដដែលនេះ ក៏ជាបញ្ជីមន្ត្រីរដ្ឋការ៦០នាក់ មកពីរបបចាស់ ដែលត្រូវបានគេសម្លាប់ចោលផងដែរ។

ចុងក្រោយបំផុត ខ្ញុំសូមយោងទៅនឹងកំណត់ត្រាដែលបានមកពីស្រុកត្រាំកក់ផងដែរ គឺ សៅ វ៉ាន់ ដែលមកពីស្រុកនោះ បង្ហាញថា នៅឆ្នាំ១៩៧៧ មានការចាប់ខ្លួនយ៉ាងច្រើនទៅលើទាហាន និង មន្ត្រីរដ្ឋការរបប លន់ នល់។ នេះគឺអ្វីដែលខ្ញុំបានលើកឡើងនៅក្នុងបទបង្ហាញរបស់ខ្ញុំរួចមកហើយ ដែលឯកសារ E3/2048។ គឺ សៅ វ៉ាន់ នេះមកពីឃុំជាងទង គាត់បានយោង សូមដកស្រង់ "ទៅលើការណែនាំជាបន្តបន្ទាប់ពីអង្គការឲ្យវែកមុខបោសសម្អាតខ្មាំង"។ បញ្ចប់ការដកស្រង់។

[១០:៤៦:៤៥]

ហើយខ្ញុំសូមធ្វើការបញ្ចប់ដោយយោងទៅលើឯកសាររបស់ ហង់រី ឡូកា ក៏ដូចជា ម៉េងទ្រី ដែលបានមកពីឯកសារសល់មកពីស្រុកត្រាំ-- គុកក្រាំងតាចាន់ ក៏ដូចជា ស្រុកត្រាំកក់ ហើយរកឃើញថា អ្នកទោសពាក់កណ្តាលនោះ ត្រូវបានគេបញ្ជូនទៅគុកក្រាំងតាចាន់នោះ គឺជានគរបាល និងជាទាហានរបប លន់ នល់។ ឯកសារយោងគឺ ហង់រី ឡូកា មាន ដែលមានចំណងជើងថា "ស្រុកត្រាំកក់" គឺឯកសារសល់ពីខ្មែរក្រហម។ ខ្ញុំមិនមាន E3 ទេ មានឯកសារ D313/1.2.16, ERN ជាភាសាខ្មែរ 00739044, អង់គ្លេស 00217700 ដល់ 701, បារាំង 00743759 ដល់ 760។ ហើយឯកសារយោងចេញពីសៀវភៅរបស់ អ៊ា ម៉េងទ្រី ដែលមានចំណងជើងថា "ខ្សែសង្វាក់នៃការបញ្ជា" E3/2120 គឺ ERN ជាភាសាអង់គ្លេស 00416399។

លោកប្រធាន លោក លោកស្រីចៅក្រម នេះ គឺជាការបញ្ចប់ការបង្ហាញឯកសាររបស់ខ្ញុំពាក់ព័ន្ធទៅនឹងគោលនយោបាយខ្មែរក្រហម ទាក់ទងទៅនឹងទាហាននៃរបបលន់ នល់។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ហើយជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តីលោក ខៀវ សំផន។ សូមអញ្ជើញបាទ!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងភាគីទាំងអស់។ យើងនឹងធ្វើការបង្ហាញឯកសារដែលពិនិត្យមើលទៅលើឯកសារមួយចំនួន។ ខ្ញុំសូមបញ្ជាក់ថា ការជ្រើសរើសយកឯកសារនេះមានភាពស្មុគស្មាញណាស់ សម្រាប់មេធាវីការពារក្តីលោក ខៀវ សំផន ពីព្រោះយើងមិនដឹងថា តើគោលជំហរជាស្ថាពររបស់អង្គជំនុំជម្រះយ៉ាងម៉េចទេ ពាក់ព័ន្ធទៅនឹងការកោះហៅសាក្សីមួយចំនួន និងអ្នកជំនាញមួយចំនួននោះ ហើយខ្ញុំគិតដល់អ្នកជំនាញ 2-TCE-92 ហើយនិង 97, 2-TCE-99។ យើងយល់ឃើញថាឯកសារមួយចំនួននោះ មិនសូវមានសារៈសំខាន់អីប៉ុន្មានទេ ពីព្រោះថាយើងបានពិភាក្សាគ្នា ហើយយើងដឹងថា យើងបានសិក្សាទៅលើឯកសារទាំងអស់នេះរួចទៅហើយ។

[១០:៤៩:៥៨]

ពាក់ព័ន្ធទៅនឹងជនជាតិចាម ឯកសារដែលខ្ញុំចង់បង្ហាញជូនភាគី និងអង្គជំនុំជម្រះនោះ គឺដំបូងគឺសម្រង់ចេញពីសេចក្តីផ្សព្វផ្សាយតាមវិទ្យុកម្ពុជាប្រជាធិបតេយ្យ គឺឆ្នាំ៧៥។ ឯកសារ E3/272 ឯកសារនេះគឺមានតែជាភាសាអង់គ្លេសទេ។ គឺ ERN លេខ 00167520 ឯកសារនេះចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ៧៥ គឺជាការផ្សាយតាមវិទ្យុ ជាការឃោសនា ហើយនៅក្នុងការឃោសនានេះគេនិយាយអំពីមូស្លីមចំណាងជើងជាភាសាអង់គ្លេសដូចតទៅ៖ "ជនជាតិចាមធានាថានឹងមានសេរីភាពពេញលេញ"។ ផលប្រយោជន៍នៃការផ្សាយតាមវិទ្យុនេះគឺ ដើម្បីបង្ហាញឱ្យឃើញថា នៅថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៧៥ នោះវាជាការសំខាន់នៅក្នុងការបង្ហាញអំពីក្រុមជនជាតិខ្មែរអ៊ីស្លាមដែលចូលរួមនៅក្នុងបដិវត្តន៍ ហើយចូលរួមនៅក្នុងកិច្ចខិតខំប្រឹងប្រែងធ្វើបដិវត្តន៍។ នេះគឺជាកម្មវត្ថុនៃការផ្សព្វផ្សាយវិទ្យុនេះ គឺជាការធ្វើឡើងសម្រាប់ផ្សព្វផ្សាយទូទាំងប្រទេស។

[១០:៥១:៣០]

ខ្ញុំសូមយោងទៅឯកសារមួយទៀត គឺឯកសារដកចេញពីប្រតិចារឹកសវនាការនៅក្នុងសំណុំរឿង ០០២/០២ គឺឯកសារ E1/192.1ដែលដកចេញពីការស្តាប់ចម្លើយអ្នកជំនាញ ហ្វីលីព ស្ហត ប្រហែល

ជាម៉ោង០៩:៣៧នាទី។ ពេលនោះគឺមេធាវី កូប៉េ ជាអ្នកសួរ គាត់លើកឡើងអំពីបញ្ហាជនជាតិវៀតណាម និងចាមជាលក្ខណ:ទូទៅ។ សម្រង់នេះគឺចាប់ផ្តើមពីម៉ោង០៩:៣៧ ខ្ញុំចាប់អារម្មណ៍ទៅលើផ្នែកទី២ នៃចម្លើយរបស់អ្នកជំនាញ ហ្វីលីព ស្ប៊ូត ពេលនោះមេធាវី កូប៉េ គាត់សួរដូចតទៅ៖ “សួរ៖ ដើម្បីត្រឡប់និយាយអំពីចម្លើយរបស់លោកកាលពីថ្ងៃចន្ទ លោកបាននិយាយពាក្យប្រល័យពូជសាសន៍។ ខ្ញុំមិនចង់សួរបញ្ហាច្បាប់ពាក់ព័ន្ធទៅនឹងចំណុចនេះទេ គឺជាអង្គជំនុំជម្រះជាអ្នកសម្រេចថាមានអំពើប្រល័យពូជសាសន៍ ឬក៏អត់?។ នៅឯកសារ៤៨៦ នៃសៀវភៅរបស់លោក គឺ ERN 00396662 លោកបាននិយាយថា ខ្មែរក្រហមមិនចង់សម្លាប់ក្រុមពូជសាសន៍ ឬក៏ក្រុមសាសនាទាំងចាម ទាំងវៀតណាម ឬក៏ខ្មែរទេ លោកបាននិយាយថា មិនមានគោលនយោបាយបែបនេះទេ ទោះបីជាខ្ញុំមិនប្រើពាក្យប្រល័យពូជសាសន៍ក៏ដោយ តើលោកចង់មានន័យថាម៉េច លោក ហ្វីលីព ស្ប៊ូត? ពេលនោះ លោក ហ្វីលីព ស្ប៊ូត គាត់បានឆ្លើយដូចតទៅ៖ ខ្ញុំពិបាកឆ្លើយទៅនឹងសំណួរនេះណាស់ ដោយមិនប្រើពាក្យប្រល័យពូជសាសន៍នោះ។ ខ្ញុំនឹងដកស្រង់ ចច ហ្សង់វែល គឺការកំណត់និយមន័យពាក្យនេះ ប្រសិនបើគេបំលែងពាក្យដើម្បីឲ្យស្របទៅនឹងនិយមន័យច្បាប់ គឺវាមានគ្រោះថ្នាក់ណាស់។ ដូច្នេះ វាពិបាកនៅក្នុងការកំណត់និយមន័យឲ្យច្បាស់។ ខ្ញុំជឿជាក់ថា មិនមានការប៉ុនប៉ងក្នុងការសម្លាប់ក្រុមពូជសាសន៍ណាមួយទេ។ ស្ថានភាពនៅកម្ពុជាខុសដាច់ពីអ្វីដែលកើតឡើងនៅ រវ៉ាន់ដាដែលពេលនោះមានការចង់សម្លាប់ជនជាតិធ្វីប។ គឺគេត្រូវតែសម្លាប់ជនជាតិធ្វីបឲ្យផុតពូជ។ នៅកម្ពុជាគឺមិនមែនអ៊ីចឹងទេ។ យើងដកស្រង់អំពីជនជាតិចាមមកធ្វើជាឧទាហរណ៍ គឺគេថាមានការប៉ុនប៉ងក្នុងការសម្លាប់ជនជាតិចាម។ ចំពោះជនជាតិចាមគឺថា ពួកគេមានវប្បធម៌ខ្លួនខុសពីខ្មែរ និងខុសពីជនជាតិផ្សេង ហើយចំពោះប៉ុល ពត និងគោលនយោ-បាយរបស់កម្ពុជាប្រជាធិបតេយ្យ គឺត្រូវធ្វើយ៉ាងម៉េចឲ្យប្រជាជនមានសិទ្ធិស្មើគ្នា។ អ៊ីចឹងព្យាយាមធ្វើយ៉ាងម៉េចឲ្យមានភាពស្មើគ្នា។ ចំពោះជនជាតិចាមគឺគេព្យាយាមបង្ក្រាប ពីព្រោះថាមានការបះបោរ។” សូមបញ្ចប់ការដកស្រង់។ នេះជាគោលជំហររបស់អ្នកជំនាញ ហ្វីលីព ស្ប៊ូត ក្នុងក្របខណ្ឌនៃសំណុំរឿង០០២/០១។

[១០:៥៥:០៧]

ឥឡូវនេះ ខ្ញុំចូលទៅនិយាយពាក់ព័ន្ធនឹងជនជាតិវៀតណាម។ ខ្ញុំបន្តពាក់ព័ន្ធទៅនឹងអ្នកជំនាញ ស្ប៊ូត ដដែល គឺឯកសារ E3/9 សម្រង់ចេញពីឯកសារពាក់ព័ន្ធទៅនឹង ប៉ុល ពត គឺ អាណាតូនី ដឺកូស្តា ERN គឺ00639721 រហូតទៅដល់ 25, ជាភាសាអង់គ្លេសគឺ 00396406 និងបន្តរហូតទៅដល់ 09។

ជាភាសាខ្មែរនោះ គឺមិនមានបកប្រែទេ។ នៅក្នុងសម្រង់ដំបូងដែលខ្ញុំចាប់អារម្មណ៍នោះគឺ លោកស្បូត គាត់លើកឡើងអំពីជម្លោះជាប្រវត្តិសាស្ត្ររវាងកម្ពុជានិងវៀតណាម។ ដូច្នេះ គាត់បានបញ្ជាក់អះអាងអំពីអ្វីដែលយើងបានស្តាប់ឮតាមរយៈសាក្សីមួយចំនួននៅក្នុងសវនាការជាពិសេសខ្ញុំយោងទៅលើសាក្សី ព្រុំ សារ៉ាត នៅក្នុងសវនាការដែលមានលេខឯកសារ E1/383.1 នៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៦ ដែលគាត់និយាយថា បញ្ហាជាមួយវៀតណាមនេះគឺគាត់ស្តាប់ឮតាំងពីសម័យជីដូនជីតារបស់គាត់ម្ល៉េះ។ ហើយនៅម៉ោង គឺនៅម៉ោង ០៩:២៩:២៤វិនាទី, ហើយសាក្សី មាស វឿន ក៏គាត់បាននិយាយនៅថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១៦ ដែរ គឺប្រហែលជាម៉ោង ១០:១៧:០៧វិនាទី។ នេះគ្រាន់តែបង្ហាញទស្សនៈជាទូទៅនៃឯកសារដែលខ្ញុំនឹងអាន។ ដូច្នេះ នៅERN ជាភាសាបារាំង 00639722 សាក្សី ហ្វីលីព ស្បូត គាត់បាននិយាយអំពីអ្វីដែលបានកើតឡើងនៅ-- ក្នុងក្របខ័ណ្ឌនៅរបបលន់នល់ អ្វីដែលកើតឡើងជាមួយវៀត-ណាម គឺនៅចុងទំព័រ នៅពេលដែលយើងរកឃើញថា ការវាយប្រយុទ្ធគ្នានោះ វាមិនមានសមត្ថភាពនោះរដ្ឋាភិបាលលន់នល់គឺបង្កការភ័យខ្លាចទៅដល់ជនស៊ីវិលវៀតណាម។ បំរាមគោចរបានដាក់ចេញចំពោះវៀតណាមដើម្បី -- ហើយដើម្បីឱ្យមានសុវត្ថិភាពនោះគេចាប់ប្រមូលជនជាតិវៀតណាមដាក់តាមជំរំ។ ផ្ទុយពីមុន ដែលកាលមុនជនជាតិវៀតណាមបានបាត់បង់ទ្រព្យសម្បត្តិទាំងអស់ ពេលនេះ គឺជាការជម្លៀសប្រជាជនចេញ គឺហើយបន្ទាប់មកទៀត គេបានបន្តទៅទៀតដោយលើកអំពីអ្វីដែលបានកើតឡើងពាក់ព័ន្ធទៅនឹងសាកសពដែលគេរកឃើញនៅអ្នកលឿង ហើយនិងសាកសពដែលបានបង្កឡើងនៅថ្ងៃទី១០ ខែមេសា។ នេះគ្រាន់តែចង់បង្ហាញ ឱ្យឃើញថា បញ្ហាវៀតណាមហ្នឹងតែងតែមានការលំបាក ហើយការលំបាកនេះ មិនមែនបង្កើតឡើង ដោយរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យទេ យើងឃើញថា វាមានតាំងពីយូរណាស់មកហើយ តាំងពីមុនរបបនោះទៅទៀត ហើយមានការកាប់សម្លាប់ទៅលើជនជាតិវៀតណាម តាំងពីពេលមុនរបបខ្មែរក្រហមទៅទៀត។ នេះជាភស្តុតាងដែលយើងរកឃើញផងដែរនៅក្នុងឯកសារមួយ គឺអត្ថបទមួយរបស់ ហង់រី ឡូកា គឺនៅក្នុងកាសែត ខេមបូឌា ដេលី ចុះថ្ងៃទី១៥ មេសា ឆ្នាំ២០១៤ គឺឯកសារ E3/7283, ERN ជាភាសាអង់គ្លេស គឺ 00993774 បន្តរហូតទៅ 75 ERNជាភាសាខ្មែរគឺ 01114245, ERNជាភាសាបារាំង គឺផ្នែកដែលពាក់ព័ន្ធដែលខ្ញុំចាប់អារម្មណ៍ គឺ-- បាទ សូមអភ័យទោស គឺមិនមាន ERNជាភាសាបារាំងទេ។ អត្ថបទសារព័ត៌មាននេះ គឺមានតែភាសាអង់គ្លេស ហើយត្រូវបានបកប្រែជាភាសាខ្មែរ។ នៅក្នុងអត្ថបទនេះ ហង់រី ឡូកា គាត់ត្រឡប់មកនិយាយអំពីបញ្ហាជនជាតិវៀតណាមនៅក្នុងរបបលន់ នល់។ ក៏មានការដកស្រង់ផងដែរ ពាក់ព័ន្ធទៅនឹងជនជាតិ

ចាម។ ខ្ញុំនឹងដកស្រង់ផ្នែកនេះ ជាភាសាអង់គ្លេសគឺ 00993774 គឺកថាខណ្ឌទីចុងក្រោយនៃទំព័រនេះ៖

[១១:០០:១៥]

“ចំពោះជនជាតិវៀតណាម មានបញ្ហើ ហើយចំពោះជនជាតិវៀតណាមវិញ គឺពួកគេជាប្រជាជនដែលអកុសលជាងគេក្នុងចំណោមប្រជាជនទាំងអស់។ ព្រោះថាប្រជាជន ប្រជាពលរដ្ឋវៀតណាមប្រមាណ៣០០ពាន់នាក់នោះ គឺថាត្រូវតម្រូវឲ្យចាកចេញពីប្រទេស។ មិនត្រឹមតែភាពច្រើននៃពួកគេដែលឆ្លៀតឱកាសនេះ ដើម្បីរត់ចេញឲ្យឆ្ងាយពីរបបដ៏គួរឲ្យស្អប់នេះទេ សូម្បីតែខ្មែរកាត់ចិន ខ្មែរដែលចេះនិយាយភាសាវៀតណាមតិចតួច ក៏បានព្យាយាមឆ្លងព្រំដែនយ៉ាងអស់សង្ឃឹមផងដែរ។ យើងមិនត្រូវភ្លេចទេថា អំពីប្រល័យពូជសាសន៍ គឺពាក្យចោទប្រកាន់ពីបទនយោបាយនៅក្នុងប្រទេសនេះ ហើយត្រូវបានគេប្រើតាំងពីខែមករា ឆ្នាំ១៩៧៩ សម្រាប់ផលប្រយោជន៍នយោបាយ។ ចំណែកជនជាតិចាមវិញពិតណាស់ ដែលថាពួកគេត្រូវរងគ្រោះច្រើនជាងក្រុមដទៃៗទៀត ប៉ុន្តែមិនមែនដោយសារមូលហេតុជាតិសាសន៍របស់ពួកគេនោះទេ។ ប៉ុន្តែដោយសារតែពួកគេបះបោរក្នុងទ្រង់ទ្រាយធំមួយនៅក្នុងស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម។ ឧទាហរណ៍ បានបដិសេធមិនព្រមផ្អាកការអធិដ្ឋានរបស់ពួកគេ។ គ្រប់សាសនាទាំងអស់ ត្រូវបានហាមឃាត់ លើកលែងតែការគោរពបូជាចំពោះអង្គការ ដោយមានការធ្វើបុណ្យ និងកិច្ចប្រជុំដ៏ធំរបស់វា។” បញ្ចប់ការដកស្រង់។

[១១:០១:៥០]

សូមបញ្ចប់ការដកស្រង់ ហើយលោក ហង់រី ឡូកា គាត់បាននិយាយថាបន្តទៀតនៅក្នុងអត្ថបទនេះថា “នៅពេលដែលយើងប្រៀបធៀបការសម្លាប់ដែលអាចកើតមានឡើងនៅក្នុងក្របខ័ណ្ឌមួយចំនួនផ្សេងទៀតនោះ គាត់មិនអាចសន្និដ្ឋានបានថា មានឆន្ទៈ ឬក៏មានចេតនាជាក់លាក់ ក្នុងការសម្លាប់ជនជាតិចាមនោះទេ។”

ឥឡូវនេះ ខ្ញុំចូលទៅសម្រង់មួយទៀត គឺដកចេញពីសៀវភៅរបស់ ហ្វីលីព ស្បូត គឺ E3/9 ដែលគាត់បាននិយាយផងដែរ អំពីការបញ្ជូនជនជាតិវៀតណាមប្រហែលជា១៥០.០០០នាក់ នៅក្នុងចន្លោះឆ្នាំ៧៣ ដល់ឆ្នាំ៧៦។ សម្រង់នេះ យើងឃើញនៅក្នុង ERN ជាភាសាបារាំងគឺ 00639840 និងERN ជាភាសាអង់គ្លេសគឺ 00396506។ សម្រង់នេះ មានសារៈសំខាន់ណាស់ ពីព្រោះថាគាត់និយាយអំពីឧប្បត្តិហេតុមួយដែលលើកឡើងដោយសាក្សី ព្រុំ សារ៉ាត នៅក្នុងសាលសវនាការកាលពីថ្ងៃទី២៧ ខែមករាកន្លងទៅនេះ គឺឯកសារ E1/383.1 ចាប់ផ្តើមពីម៉ោង១១:១០:០៤វិនាទី នៅពេលដែលគាត់ឆ្លើយទៅ

នឹងសំណួររបស់លោកចៅក្រម ឡាវែន៍។

នេះជាសម្រង់ដែលខ្ញុំសូមដកស្រង់ អ្នកជំនាញ ហ្វីលីព ស្សូត គាត់និយាយអំពីទំនាក់ទំនងរវាងវៀតណាមនិងកម្ពុជា។ គាត់បាននិយាយថា ខ្ញុំសូមដកស្រង់៖ “នៅដើមខែសីហា មានអ្នកកាសែតវៀត-ណាមមកទស្សនកិច្ចនៅកម្ពុជា ហើយមានការទទួលយ៉ាងកក់ក្តៅ។ ប៉ុន្មានថ្ងៃក្រោយមក វ៉ើន វ៉ាន់ លីញ បានប្រាប់ នួន ជា កងវៀតណាមនោះ ត្រៀមខ្លួននឹងដោះលែងទាហានខ្មែរក្រហមដែលខ្លួនបានចាប់នៅកោះល្វៃនោះ។” ខ្ញុំសូមបញ្ចប់ត្រឹមនេះ ហើយខ្ញុំគ្រាន់តែបញ្ជាក់ថា ហេតុការណ៍នេះ ក៏ត្រូវបានលើកឡើងដោយ ព្រំ សារ៉ាត នៅក្នុងសវនាការដែលខ្ញុំបានបញ្ជាក់កាលពីមុនបន្តិចនេះ។

ខ្ញុំសូមបន្តទៅទៀត៖ “ការផ្លាស់ប្តូរសារគ្នានេះ បង្ហាញឲ្យឃើញពីសាមគ្គីភាពមិនអាចសាបសូន្យរវាងភាគីទាំងពីរ។ ការិយាល័យទំនាក់ទំនងគ្នា ត្រូវបានបង្កើតឡើងនៅតាមព្រំដែន ដើម្បីឲ្យមានការសហការគ្នាឲ្យបានល្អ។ ការបញ្ជូនប្រជាជនវៀតណាមទៅវៀតណាមវិញ គឺនៅតែបន្តទៅទៀត។ ហើយមានជនជាតិវៀតណាមត្រូវបានបញ្ជូនទៅវៀតណាមវិញ ហើយជនភៀសខ្លួនដែលរត់ទៅវៀត-ណាមនោះ ក៏ត្រឡប់មកខ្មែរវិញដែរ។” សូមបញ្ចប់ការដកស្រង់។

[១១:០៤:៥២]

នេះជាសម្រង់ដ៏សំខាន់ពាក់ព័ន្ធទៅនឹងបញ្ហាប្រវត្តិសាស្ត្រ ដែលបង្ហាញឲ្យឃើញអំពីទំនាក់ទំនងល្អរវាងកម្ពុជានិងវៀតណាម។ ហើយវាបង្ហាញឲ្យឃើញថា វាពិតជាមានការចាប់ខ្លួនទាហានខ្មែរក្រហមយកមកធ្វើឈ្លើយសឹក ហើយនៅក្រោយថ្ងៃទី១៧ មេសា នោះ យើងឃើញថាមានការចរចាគ្នា ដែលមានរយៈពេលជាច្រើនខែ ហើយខ្ញុំនឹងត្រឡប់មកនិយាយអំពីចំណុចនេះនៅពេលបន្តិចទៀត។ ឥឡូវហ្នឹង ខ្ញុំសូមចូលទៅឯកសារមួយទៀត ដែលខ្ញុំចង់បង្ហាញជូន គឺការដកស្រង់ចេញពីអត្ថបទរបស់ ហ្វ្រង់ស្វ័រ ប៉ុងស្វដ៍ គឺឯកសារ E3/4589, ERN ជាភាសាបារាំង គឺ00283070, ERN ជាភាសាខ្មែរ គឺ 00323746, ERN ជាភាសាអង់គ្លេស គឺ00323699។ អ្វីដែលសំខាន់នេះ គឺអត្ថបទនេះ គឺចុះថ្ងៃទី១០ ខែមករា ឆ្នាំ៧៦។ យើងត្រូវតែមានការប្រយ័ត្នប្រយែងចំពោះសេចក្តីថ្លែងការណ៍របស់ជនភៀសខ្លួន ពីព្រោះថា ក្នុងអត្ថបទនេះ ហ្វ្រង់ស្វ័រ ប៉ុងស្វដ៍ គាត់បាននិយាយអំពីអ្វីដែលខ្លួនបានស្តាប់ឮពីជនភៀសខ្លួននៅតាមព្រំដែន។ នៅក្នុងសម្រង់នេះ ដែលបញ្ចប់នៅក្នុងចុងលេខ ERN គឺ70 នៅទំព័រ១៦ ជាភាសាបារាំង គាត់បាននិយាយអំពីវត្តមានរបស់វៀតណាម ដែលមាននៅឡើយនៅក្នុងតំបន់មួយចំនួននៅតាមនៅប្រទេសកម្ពុជា។ ហើយគាត់បានសួរថា តើពួកគេនៅតែមានវត្តមានឬក៏យ៉ាងណា? ពេលនោះ

ប៉ុងសូង៍ គាត់បានសរសេរដូចតទៅ៖

"ផ្ទុយទៅវិញ ពួកវៀតណាមនៅកម្ពុជា មានលទ្ធភាពត្រឡប់ទៅប្រទេសដើមកំណើតរបស់ខ្លួនវិញ ចាប់តាំងដើមខែមិថុនាមកម្ល៉េះ។ នាយទាហានម្នាក់មកពីដាយហ្វុង គឺរណសិរ្សរំដោះជាតិវៀតណាមខាងត្បូង បានមកប្រាប់ប្រជាជននៅចំការលើនៅថ្ងៃទី០៣ ខែមិថុនា ថា ប្រជាជនទាំងបី មានវៀតណាម កម្ពុជា ឡាវ ជាបងប្អូននឹងគ្នា ហើយបើពួកវៀតណាមចង់ត្រឡប់ទៅប្រទេស មាតុប្រទេសវិញ ពួកគេអាចទៅវិញបាន។ ពួកអ្នកភ្នំពេញជាច្រើន បានប្រាប់គេថាខ្លួនជាជនជាតិវៀតណាម ហើយបានទៅប្រទេសវៀតណាមចាប់តាំងពីថ្ងៃទី០៦ ខែមិថុនា មកម្ល៉េះ។ នៅតាមផ្លូវ ពួកគេបានជួបកម្មាភិបាលវៀតកុងជាច្រើនដែលបានមករស់នៅប្រទេសកម្ពុជាជាច្រើនមកហើយ ហើយពួកគេត្រឡប់ទៅវៀតណាមជាមួយគ្រួសារ និងទ្រព្យសម្បត្តិរបស់ពួកគេវិញ។ កម្មាភិបាលទាំងអស់នេះ បានធ្វើមាតុភូមិនិវត្តតាមឡានកាំម៉្មុង រីឯខ្មែរដែលថាខ្លួនជាជនជាតិវៀតណាមនោះ ត្រូវធ្វើដំណើរដោយថ្មើរជើង។"

[១១:០៨:១០]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

សូមលោកៗស្រីមេធាវី សុំឲ្យបន្ថយល្បឿនបន្តិច ពីព្រោះពិបាកណាស់ សម្រាប់អ្នកបកប្រែលឿនពេក។

**កញ្ញា អង់តា ហ្គីសសេះ៖**

សូមអភ័យទោស ខ្ញុំនឹងព្យាយាមបន្ថយល្បឿន និយាយដោយយឺតៗ។

នៅក្នុងសម្រង់នេះ បញ្ហាដែលបានជជែកវែកញែកនោះ ហើយក៏មានការពិភាក្សាគ្នាជាច្រើនដងច្រើនលើកនៅក្នុងសវនាការ គឺនិយាយអំពីការចរចា ដើម្បីបញ្ជូនកម្មាភិបាលវៀតណាមមួយចំនួនដែលមានវត្តមានកម្ពុជាទៅៗវៀតណាមវិញ។ ដូច្នេះគេមានការពិភាក្សាអំពីបញ្ហាហ្នឹងមែន។ ហើយ ប៉ុងសូង៍ គាត់បាននិយាយបន្តទៅទៀតថា៖ "នៅពេលជាមួយគ្នានោះ មានវេជ្ជបណ្ឌិតម្នាក់មកពីបាត់ដំបង បានទទួលការអនុញ្ញាតឲ្យទៅនៅ -- ឲ្យទៅសៃហ្គន។ ប្រហែលខែកក្កដា មានគណៈប្រតិភូវៀតណាមមួយក្រុម បានមកស្វែងរកជនជាតិវៀតណាម នៅតាមតំបន់តាខ្មៅ ហើយក្នុងដំណើរម្តងៗបានបញ្ជូនមនុស្សពី៥០០ ទៅ១០០០នាក់ ទៅវៀតណាម។ សាក្សីម្នាក់បានបន្ថែមថា នៅតំបន់បាណាម រឹតតែមានច្រើនជាងនេះទៅទៀត។ នៅចុងខែតុលាជនជាតិវៀតណាមចំនួន៦០០នាក់ មកពីតំបន់បាត់ដំបង បានធ្វើមាតុភូមិនិវត្តតាមទូកតូចៗបី។ ពួកគេបានចាកចេញពីមង្គលបុរី កាត់តាមភ្នំពេញដោយមិនមានឈប់

សម្រាកទេ។ នៅថ្ងៃទី០៨ ខែវិច្ឆិកា នៅពេលដែលស្រូវទុំល្អមនឹងច្រូតកាត់ អាជ្ញាធរបានតម្រូវឲ្យពួកយើង គឺពួកវៀតណាមពីក្រូចឆ្មារ ឲ្យចាកចេញពីកម្ពុជាទៅវៀតណាម។ មានតែគ្រួសារប្រាំមួយ តែប្រាំពីរ -- ប្រាំមួយ ឬប្រាំពីរប៉ុណ្ណោះ បានទទួលការអនុញ្ញាតឲ្យពន្យារពេលចេញដំណើរ។” សូមបញ្ចប់ការដកស្រង់។

ដូច្នេះ នេះជាសក្ខីកម្មរបស់ជនភៀសខ្លួនដែលដកស្រង់ដោយ ហ្វ្រង់ស្វ័រ ប៉ុងស្វដ៍ គឺបង្ហាញឲ្យឃើញច្បាស់ថា មានការព្រមព្រៀងគ្នារវាងរដ្ឋកម្ពុជា និងរដ្ឋវៀតណាម ដើម្បីបញ្ជូនជនជាតិវៀតណាមត្រឡប់ទៅស្រុកវិញ។ ដូច្នេះ ក្នុងនេះយើងឃើញថាមានគណៈប្រតិភូវៀតណាមមកស្វែងរកជនជាតិវៀតណាម។ ចំណុចនេះ គឺសំខាន់ណាស់ដែលយើងត្រូវតែកត់សម្គាល់។

[១១:១០:៣២]

យើងបន្តទៅទៀតតាមលំដាប់កាលប្រវត្តិ។ ខ្ញុំសូមនិយាយអំពីសម្រង់មួយចេញពីសៀវភៅរបស់ ហ្វីលីព ស្សត គឺ E3/9 គឺ ERN ជាភាសាបារាំង 00639952, ERN ជាភាសាអង់គ្លេស 00396587 ទៅដល់ 88។ យើងឃើញថា បាននិយាយអំពីកាលប្រវត្តិនោះ គឺភាគីរដ្ឋទាំងពីរចរចាគ្នាដើម្បីឲ្យមានការបញ្ជូនជនជាតិវៀតណាមទៅស្រុកវិញ ហើយក្នុងនោះយើងឃើញមានឆន្ទៈនៅក្នុងការពិភាក្សាចរចាគ្នា គឺវានៅជិតឆ្នាំ៧៧ ឆ្នាំ៧៨ ហើយនៅក្នុងសម្រង់នេះ ហ្វីលីព ស្សត និយាយអំពីវត្តមាននៃជំរំហ្វឹកហាត់សម្រាប់ជនភៀសខ្លួនខ្មែរនៅវៀតណាម។ ERN ជាភាសាបារាំង 00639951 គឺពីរបន្ទាត់ចុងក្រោយនៅក្នុងទំព័រនេះ។

[១១:១១:៥៦]

នៅដើមរដូវក្ដៅឆ្នាំ៧៨ គឺវៀតណាមនិងចិនបានជម្នះនូវភាពអល់អែក ហើយបានសម្រេចដោះស្រាយបញ្ហាដែលចៀសមិនរួច។ ជនជាតិវៀតណាម បានបង្កើតជំរំហ្វឹកហាត់សម្រាប់ជនភៀសខ្លួនខ្មែរនៅក្នុងអតីតមូលដ្ឋានយោធាអាមេរិក នៅភាគខាងជើងនៃប្រទេស -- នៅភាគខាងត្បូងនៃប្រទេស។ ឡី យន់ និង ឡី ឌឹកថូ បានជួបគ្នាជាលើកដំបូង គឺបានជួបទៅនឹងមេដឹកនាំនៃចលនាតស៊ូខ្មែរនាពេល អនាគត។ សឺង ង៉ុកមិញ ដែលបានដឹកនាំបក្សកម្ពុជានៅដើមឆ្នាំ៥០ ទទួលរងនូវការ -- រងនូវជំងឺនៅឆ្នាំ១៩៧២ ក៏ប៉ុន្តែសហការីរបស់គាត់នៅវៀតណាមខាងជើង ហើយបន្ទាប់មកបានចូលរួមជាមួយខ្មែរក្រហម ហើយបានរត់គេចក្រោយឆ្នាំ១៩៧៥។ ទាំងអស់នេះ សុទ្ធតែជាអ្នកដែលមានឋានៈតូចទាប។ ប៉ែន សុវណ្ណ ដែលធ្វើការឲ្យវិទ្យុរបស់ហ្វុង នៅដើមឆ្នាំ៧០ នោះ គឺគាត់បានកាន់តំណែងជាមេបញ្ជាការ

នៅក្នុងកងទ័ពវៀតណាម។ ប៊ូ ថង ក៏ជាអតីតយុទ្ធជនឥស្សរៈដែរ ហើយ ហ៊ុន សែន ក៏ជាអតីតមេបញ្ជាការយោធាខ្មែរក្រហមវ័យក្មេង ពួកគេបានផ្តាច់ខ្លួននៅឆ្នាំ១៩៧៧ ហើយមានកម្មវិធីបំពាក់បំប៉នមនោគមវិជ្ជា នៅខែ -- ហើយនៅខែមេសា យើងឃើញមានកងវរសេនាតូចមួយរបស់ទាហានបះបោរបានចូលមក។

[១១:១៣:៤១]

ដូច្នេះ យើងឃើញថា នេះជាភស្តុតាងដ៏សំខាន់ ហើយអង្គជំនុំជម្រះបានបែងចែករវាងក្រុមជាក់លាក់ និងជម្លោះប្រដាប់អាវុធ ក៏ប៉ុន្តែនៅក្នុងក្របខ័ណ្ឌ នៅក្នុងទស្សនៈរបស់មេធាវីការពារក្តី គឺយើងមិនអាចបំបែកចំណុចនេះចេញពីគ្នាបានទេ។ ហើយយើងក៏បានស្តាប់ឮពីសាក្សីមួយចំនួនពាក់ព័ន្ធទៅនឹងការចាប់ខ្លួនមនុស្សជាច្រើន ហើយមានការចោទប្រកាន់ថា មានការធ្វើទុក្ខបុកម្នេញ មានការបះបោរ។ ដូច្នេះ យើងត្រូវតែពិនិត្យមើលបរិបទឲ្យបានច្បាស់ថា តើមានអ្វីកើតឡើងនៅខាងវៀតណាម ហើយនិងនៅព្រំដែនវៀតណាម។ វាពិតជាមានផលប៉ះពាល់មកលើអ្វីដែលបានកើតឡើងនៅក្នុងទឹកដីកម្ពុជា។

ឯកសារមួយទៀត ដែលអាចឲ្យយើងលើកឡើងផងដែរនោះ គឺបង្ហាញអំពីការបះបោរ ការងើបឡើង ហើយនិងការផ្តាច់ខ្លួនចេញពីរបបខ្មែរក្រហម គឺអត្ថបទរបស់ វ៉ាស៊ីនតោនប៉ុស្តិ៍ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ១៩៧៨ គឺឯកសារលេខ E3/7265 ដែលមានតែជាភាសាអង់គ្លេស និង ខ្មែរ។ ERN ជាភាសាអង់គ្លេសគឺ 00166105, ERN ជាភាសាខ្មែរ 00 -- (សូមទោស) 01081608 ទៅដល់ 610។

ខ្ញុំនឹងមិនអានអត្ថបទនេះទាំងស្រុងទេ ក៏ប៉ុន្តែខ្ញុំសូមដកស្រង់តែមួយចំណុចតែប៉ុណ្ណោះ គឺជាពិសេសគឺសេចក្តីផ្តើម។ ខ្ញុំសូមដកស្រង់ជាភាសាអង់គ្លេស៖

[១១:១៥:៣១]

"ប្រទេសវៀតណាម ដែលជាប់ពាក់ព័ន្ធនឹងសង្គ្រាមព្រំដែនជូរចត់ជាមួយនឹងប្រទេសកម្ពុជា កំពុងរាយការណ៍ថា សញ្ញានៃការបះបោរបានផ្ទុះឡើងនៅក្នុងទូទាំងប្រទេសកម្ពុជាជាច្រើនសប្តាហ៍កន្លងទៅនេះ។ ឃើញថាប្រទេសនេះក៏បាននិយាយថា អ្នកបះបោរភាគច្រើនគឺធ្វើឡើងដោយអង្គភាពកងទ័ពធម្មតា។ ក្រុមអ្នកវិភាគនៅទីក្រុងវ៉ាស៊ីនតោនបាននិយាយថា ពួកគេគ្មានវិធីបញ្ជាក់ពីសេចក្តីរាយការណ៍ដែលផ្សព្វផ្សាយប្រព័ន្ធផ្សព្វផ្សាយវៀតណាមទេ ហើយពួកគេសង្ស័យថា រដ្ឋាភិបាលនៅទីក្រុងហាណូយកំពុងរៀបចំចលនាបដិវត្តន៍កម្ពុជា ដើម្បីដាក់សម្ពាធលើទីក្រុងភ្នំពេញឲ្យដោះស្រាយជម្លោះហិង្សារបស់ពួកគេ។"

[១១:១៦:១៦]

ខ្ញុំនឹងរំលងកថាខណ្ឌមួយចំនួន ហើយខ្ញុំសូមបន្តដកស្រង់ទៅទៀតជាភាសាអង់គ្លេស៖

"អ៊ីចឹងយើងមើលទៅតាមរបាយការណ៍ យើងឃើញថាវាបានពាក់ព័ន្ធជាមួយនឹងកត្តាពាក់ព័ន្ធទៅនឹង១នេះដែរ គឺវាមានការផ្សាយចេញពី បីដងក្នុងមួយសប្ដាហ៍ចាប់តាំងពីពាក់កណ្ដាលខែមិថុនា។ នៅពេលនោះ សេចក្ដីថ្លែងការណ៍មួយដែលត្រូវបានចាត់ទុកថា ធ្វើឡើងដោយអតីតមេបញ្ជាការកងវរសេនាតូចនៅប្រទេសកម្ពុជាបានលើកឡើងថា កងកម្លាំងបដិវត្តន៍បានបង្កើតមូលដ្ឋានដើម្បីប្រយុទ្ធប្រឆាំងជាមួយរដ្ឋាភិបាលទីក្រុងភ្នំពេញ។ គេនិយាយថា មូលដ្ឋាននេះស្ថិតនៅក្នុងតំបន់យោធា២០៣ របស់ប្រទេសកម្ពុជាដែលប្រភពស៊ើបការណ៍ជឿជាក់ថា គឺជា -- នៅជិតមេមត់ដែលជាទីក្រុងប្រជុំជនរបស់ប្រទេសកម្ពុជាមានចម្ងាយប្រហែល ៦ម៉ាយល៍ ពីព្រំប្រទល់នៃប្រទេសវៀតណាម។ ចាប់តាំងពីពេលនោះមក គេបាននិយាយថាការបះបោរជាច្រើនបានកើតឡើងតាំងទី នៅតាមទីប្រជុំជន និងភូមិនានាក្នុងប្រទេសកម្ពុជា។ ភាគច្រើននៃការបះបោរទាំងនោះស្ថិតនៅក្នុងភាគខាងកើតនៃប្រទេស ដូចជា ស្នួល, អ្នកលឿង និងស្វាយរៀង។ ហើយក៏វាបានបញ្ជាក់ថា ការបះបោរនេះ គឺកើតឡើងនៅផ្នែកមួយផ្សេងទៀតនៃប្រទេសកម្ពុជាដូចជា ខេត្តបាត់ដំបង និងជាប់នៅភាគខាងលិចនឹងកំពង់ធំ និងភាគខាងជើងនៃប្រទេស។ អតីតទាហានកម្ពុជាម្នាក់បានរៀបរាប់ពីជនស៊ីវិលរួមបញ្ចូលទាំងមន្ត្រីរាជការ កម្មករតាមចម្ការ និងកសិករដែលបានងាកមកប្រឆាំងនឹងកម្មាភិបាលឃោរឃៅ ព្រមទាំងប្រល័យពួកវាដោយគ្រាប់បែក និងព្រនង់។"

[១១:១៨:០៦]

នេះដើម្បីបង្ហាញអំពីបរិបទ ហើយជាចុងក្រោយ អត្ថបទនេះបានបញ្ចប់ដូចតទៅ ខ្ញុំសូមដកស្រង់គឺកថាខណ្ឌចុងក្រោយតែម្ដង៖ "អ្នកវិភាគបានបញ្ជាក់ថា វាមានការពាក់ព័ន្ធទៅនឹងការបះបោរជាច្រើន ជាពិសេសអាស្រ័យទៅតាមអ្វីដែលបញ្ជាក់នោះ"។ គឺសូមបញ្ចប់។

នេះជាភស្តុតាងអំពីបរិបទដ៏សំខាន់ ដែលបង្ហាញអំពីភាពតានតឹងកាន់តែកើនឡើងខ្ពស់នៅក្នុងប្រទេសកម្ពុជានៅក្នុងភូមិភាគបូព៌ា ហើយក៏មានការកើនឡើងសម្ពាធខ្លាំងពាក់ព័ន្ធទៅនឹងការពិភាក្សាគ្នាជាមួយវៀតណាម។ ហើយវាកើនឡើង តានតឹងឡើងដល់ចំណុចកំពូល។ ហើយក្រោយមកក៏មានការមកដល់ជនជាតិ -- នៃទាហានវៀតណាមនៅឆ្នាំ៧៩ នោះ។ ខ្ញុំសូមយោងទៅឯកសារមួយទៀត គឺ E3/7310 ដែលជាអត្ថបទបង្ហាញអំពីទំនាក់ទំនងចុងបូព៌ានៅថ្ងៃទី០៥ ធ្នូ ឆ្នាំ១៩៧៨ ដែលនិយាយអំពី

ការបង្កើតរណសិរ្សរួបរួមជាតិកម្ពុជា។ ហើយការបង្កើតហ្នឹង គឺដើម្បីផ្តួលរលំរបបភ្នំពេញ។ នេះគឺជាការបង្ហាញរបាយការណ៍ផ្លូវការ។ ខ្ញុំសូមយោងទៅ ERN ជាភាសាអង់គ្លេសគឺ S0013294, ERN ជាភាសាខ្មែរ S01113752។

[១១:២០:១២]

នេះជាការបង្ហាញអំពីចលនាមួយនេះ។ ខ្ញុំសូមដកស្រង់ជាភាសាអង់គ្លេសដោយសារថាមិនមានជាភាសាខ្មែរទេ -- ជាភាសាបារាំងទេ សុំទោស។

"វាពិតជាសំខាន់ណាស់ដែលវាកើតឡើងនៅក្នុងប្រទេស កម្ពុជា នៅក្នុងទីតាំងមួយចំនួននៃតំបន់រំដោះរបស់ប្រទេសកម្ពុជា។ សមាជិកនៃតំណាងសម្រាប់បង្កើតរណសិរ្សជាតិកម្ពុជា ដើម្បីសង្គ្រោះជាតិត្រូវបានប្រារព្ធឡើងយ៉ាងអធិកអធម និងប្រកបដោយភាពជោគជ័យ។ អ្នកចូលរួមនៅក្នុងសមាជនេះរួមមានតំណាងគ្រប់ស្រទាប់វណ្ណៈនៃប្រជាជនស្នេហាជាតិកម្ពុជា ក្នុងនោះ មានកម្មករ កសិករ គហបតីតូចតាច បញ្ញវន្ត ព្រះសង្ឃ និងដូនជី យុវជន ស្ត្រី ជនជាតិដើមភាគតិចកម្ពុជា និងអ្នកបះបោរស្នេហាជាតិ ដែលបានបះបោរ ដែលបានបោះបង់ចោលរដ្ឋបាល និងកងទ័ពរបស់ ប៉ុល ពត, អៀងសារី។" សូមបញ្ចប់។

[១១:២១:២២]

ខ្ញុំសូមយោងទៅលើអត្ថបទមួយទៀតផងដែរ ដែលស្ថិតនៅក្នុងកម្រងនៃអត្ថបទផ្សេងៗអំពីរបបនោះ ជាពិសេសគឺខ្ញុំយោងទៅលើអត្ថបទមួយរបស់ភ្នំពេញ អ៊ីនសីវ៉ិស, ERN ជាភាសាអង់គ្លេស S0013305 ខ្ញុំបាត់ ERNជាភាសាខ្មែរ រកមិនឃើញ ក៏ប៉ុន្តែអត្ថបទនេះមានចំណងជើងជាភាសាអង់គ្លេសថា "វៀតណាមបានបង្កប់គិញនៅក្នុងជនភៀសខ្លួនកម្ពុជា"។ ដូច្នេះយើងឃើញថា នៅចុងឆ្នាំ១៩៧៨ គឺមានការបះបោរដល់កំពូល ហើយយើងនិយាយអំពីការផ្តាច់ខ្លួន ហើយក៏និយាយអំពីក្រុមហើយនិងកងទ័ពដែលប្រឆាំងទៅនឹងរបបភ្នំពេញ។ ខ្ញុំសូមយោងទៅលើឯកសារ E3/7315 ដែលជាអត្ថបទរបស់ អេស.ដាប់ប៊ែលយូ.ប៊ី ទំនាក់ទំនងចុងបូព៌ា គឺថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៧៨ នៅទំព័រដំបូងនោះគឺ S01137156 ជាភាសាខ្មែរ, ជាភាសាអង់គ្លេសគឺ S00013209 បន្តរហូតទៅដល់ទំព័របន្តបន្ទាប់ទៀត ដែលក្នុងឯកសារនេះ និយាយអំពីវត្តមានរបស់កងពល កងទ័ពវៀតណាម ហើយក្នុងទំព័រដំបូងដែលខ្ញុំដកស្រង់នោះ គឺចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៧៨ ដកចេញពីសារព័ត៌មានបាងកកប៉ុស្តិ៍ ជាភាសាអង់គ្លេស។ ខ្ញុំសូមដកស្រង់ជាភាសាអង់គ្លេស៖

[១១:២៣:៤៧]

“តាមរបាយការណ៍សម្ងាត់បានបញ្ជាក់ថា គឺគេឃើញថាមានចំនួនទ័ពសរុបប្រហែលជា ៦០.០០០ នាក់ និងបំពាក់ដោយអាវុធគ្រប់គ្រាន់ និងចូលកាន់កាប់ទឹកដីប្រទេសកម្ពុជានៅតាមបណ្ដោយព្រំដែនពីខាងកើត ទាំងមូលនៃប្រទេសកម្ពុជា។ របាយការណ៍នេះបានរាយការណ៍ថា ក្រុមកម្លាំងតស៊ូខ្មែរគាំទ្រដោយវៀតណាម ដែលចូលកាន់កាប់ ចូលទៅកាន់កាប់ខេត្តកំពង់ចាម ខេត្តរតនគិរី ស្រុកស្នួល និងតំបន់យុទ្ធសាស្ត្រដែលស្ថិតនៅភាគខាងកើតនៃទន្លេមេគង្គ។” ពីរកថាខណ្ឌចុះមកក្រោមទៀត អត្ថបទនេះបានសរសេរបន្តទៅទៀត៖

“ទន្ទឹមនឹងនោះដែរ គេបានបញ្ជាក់ថា កាលណារបប ប៉ុល ពត កាន់តែខ្សោយនោះ ប្រទេសចិននឹងចូលកាន់កាប់ក្នុងប្រទេសកម្ពុជា។ ពួកគេអះអាងថា រដ្ឋាភិបាលនេះកំពុងបោះបង់ប្រជាប្រិយភាពក្នុងចំណោមប្រជាជនដោយសារតែការសម្លាប់រង្គាល។ ជាពិសេសតាមរយៈវៀតណាមខាងត្បូង ដែលគេអនុវត្តកន្លងមកនោះ។” អ៊ីចឹងសូមបញ្ចប់ការដកស្រង់។

[១១:២៤:៥២]

នេះជាឧទាហរណ៍មួយចំនួន ដែលដកស្រង់ចេញពីអត្ថបទកាសែតនានា ដែលបង្ហាញអំពីការរុលចូលនៃចលនាបះបោរចូលមកកម្ពុជាប្រជាធិបតេយ្យដែលមានការគាំទ្រពីសំណាក់វៀតណាម។ ចំណុចមួយទៀត ដែលខ្ញុំចង់លើកឡើងពាក់ព័ន្ធទៅនឹងបញ្ហាវៀតណាមនេះ គឺឃ្លាមួយនៃឯកសារ E3/3995 ដែលជាអត្ថបទរបស់ ស្ទីវ ហេដឌ័រ។ ចំណុចដែលខ្ញុំចាប់អារម្មណ៍ខ្លាំងនោះ គឺការវិភាគរបស់គាត់ពាក់ព័ន្ធទៅនឹងពាក្យ “ក្បាលយួនខ្លួនខ្មែរ” ដែលពាក្យនេះ ក៏ត្រូវបានលើកឡើងនៅក្នុងសវនាការយើងនេះ ជាច្រើនលើកច្រើនសាមកហើយ។ ឯកសារដដែល គឺឯកសារ E3/3995, ERN ជាភាសាបារាំង 00802832, ERN ជាភាសាខ្មែរ 00844612 បន្តទៅទំព័របន្ទាប់ទៀតហើយ ERN ជាភាសាអង់គ្លេស គឺ 00773767។ ខ្ញុំសូមបញ្ជាក់ថា អត្ថបទនេះមានចំណងជើងថា -- អត្ថបទនេះ គឺជាការរិះគន់ ទៅលើសៀវភៅរបស់ ប៉ែន ឃៀរនិន មានចំណងជើងថា “ជាតិសាសន៍និយម លទ្ធិម៉ាក្សនិយម ការប្រសិទ្ធ-នាម និងអំពើប្រល័យពូជសាសន៍” នៅក្នុងសៀវភៅដែលមានចំណងជើងថា របបប៉ុល ពត។

[១១:២៦:៥០]

នៅក្នុងការព្យាយាមទទ្បីករណ៍របស់ខ្លួន ប៉ែន ឃៀរនិន បាននិយាយថា “ជនរងគ្រោះជាច្រើននៅភូមិភាគបូព៌ា ត្រូវបាននិយាយថា -- ត្រូវបានគេចាត់ទុកថាជាក្បាលយួន ខ្លួនខ្មែរ”។ ហើយគាត់បាន

បង្ហាញថា "អ្នកទាំងអស់ហ្នឹង គឺត្រូវបានគេសម្លាប់ចោល"។ ពាក្យ "ក្បាលយួនខ្លួនខ្មែរ" នេះ ក៏ត្រូវបានប្រើប្រាស់ពីមុនមកដែរ ដើម្បីបង្ហាញអំពីរូបភាពនយោបាយខ្មែរ នៅក្រោមការគ្រប់គ្រងរបស់វៀត-ណាម។ ទស្សីករណ៍របស់ ប៉ែន យៀវនិន ដែលថា ពាក្យនេះត្រូវបានប្រើប្រាស់ដើម្បីកម្ទេចជនជាតិខ្មែរភាគច្រើន ដោយមានការរើសអើង ដែលថាពួកគាត់មិនមែនជាខ្មែរ។ ហើយពាក្យនេះគឺមានន័យថា ជាការដឹកនាំ ការតម្រង់ទិសនយោបាយដែលបានកំណត់តាមរបៀបមនោគមវិជ្ជា។ ដូច្នេះ ការក្បត់ និងវណ្ណៈ ហើយនិងបុព្វហេតុជាតិនោះ ត្រូវបាន ដែលចាត់ទុកថាជាអ្នកមិនគោរពតាមគោលនយោបាយនៃវណ្ណៈអធន ទោះបីជាអ្នកនោះមានពណ៌សម្បុរយ៉ាងម៉េចក៏ដោយ។ ដូច្នេះ ការរិះគន់នេះមានសារៈសំខាន់ណាស់ ព្រោះថានៅពេលដែលយើងនិយាយអំពីប្រល័យពូជសាសន៍នោះ គឺសហព្រះរាអាជ្ញាតែងតែលើកនិយាយអំពីពូជសាសន៍ ហើយត្រង់ចំណុចនេះ ស្ទីវ ហេដឌ័រ គាត់បង្ហាញអំពីបរិបទផ្សេង ដោយបានរំឭកថាបញ្ហាមិនមែនមកពីពូជសាសន៍ទេ គឺជាបញ្ហានយោបាយ ហើយនិងការប្រឆាំងទៅនឹងគោលនយោបាយ។ នេះជាការរិះគន់ដែលយើងអាចរកឃើញផងដែរ នៅក្នុងសៀវភៅរបស់ ហង់រី ឡូកា។ គឺនៅក្នុងឯកសារ E3/7280 ឯកសារនេះ មានតែជាភាសាបារាំងប៉ុណ្ណោះ។ ERN គឺ 00995818 គឺជាអត្ថបទដែលមានចំណងជើងថា៖ "ការក្រឡេកមើលមិនច្បាស់ទៅលើកម្ពុជា" ដែលបោះពុម្ពនៅក្នុងសារព័ត៌មានឡឺម៉ុងដ៍ នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ១៩៨៨។

ដូច ស្ទីវ ហេដឌ័រ ដែរ ហង់រី ឡូកា គាត់រិះគន់ទៅលើទស្សនៈរបស់ ប៉ែន យៀវនិន។ គាត់បាននិយាយដូចតទៅ ខ្ញុំសូមដកស្រង់ ខ្ញុំអានយឺតៗ ដែលសារតែមិនមានការបកប្រែជាលាយលក្ខណ៍អក្សរទេ។ គឺ ERN00995818 កថាខណ្ឌចុងក្រោយជាភាសាបារាំង៖ "ច្បាស់ណាស់ យើងមិនអាចពិនិត្យផ្ទៀងផ្ទាត់ភស្តុតាងជាច្រើនដែល យៀវនិន យកមកអះអាង ដើម្បីបង្ហាញពីទស្សនៈរបស់ខ្លួនទេ។ ខ្ញុំអាចដកស្រង់នូវអង្គហេតុបី ដែលបង្ហាញឲ្យឃើញពីការពិតនៃពិភពខ្មែរក្រហមក្នុងក្របខ័ណ្ឌចង្អៀត ដែលបានលើកឡើងដោយអ្នកនិពន្ធ។" មួយ ទោះបីជាមានការសន្និដ្ឋានក៏ដោយ យៀវនិន មិនអាចបង្ហាញថាជនភាគតិច គឺជាជនរងគ្រោះនៃការបង្ក្រាបនោះទេ។ ប្រសិនបើជនជាតិភាគតិចវៀតណាមដែលត្រូវៗបានបណ្តេញចេញ អារម្មណ៍ស្អប់វៀតណាម គឺកើតមាននៅក្នុងចំណោមប្រជាជនខ្មែរ ហើយគេបង្កើតមុនតាំងពីពេលខ្មែរក្រហមទៅទៀត។ ហើយមានភាពរីកសុះសាយរហូតមកដល់សព្វថ្ងៃនេះ។ ផ្ទុយនឹងការអះអាងរបស់ហាណ្ឌយដែលបានលើកឡើងដោយ យៀវនិន មេដឹកនាំកម្ពុជាប្រជាធិបតេយ្យ មិនមានការប៉ុនប៉ងក្នុងការវាយយកកម្ពុជាក្រោមទេ។ ចាមដែលជាជនជាតិភាគតិច ហើយដែលមិនមែនជា

ជនជាតិខ្មែរនោះ គឺបានស្លាប់អស់ជាច្រើននាក់ក្នុងចំណោមប្រជាជនរបស់ខ្លួន ពីព្រោះថា អ្នកភូមិមួយ - - ភូមិមួយចំនួននៅតាមដងទន្លេមេគង្គបានងើបឡើងបះបោរ ហើយមិនត្រូវបានគេអនុញ្ញាតឲ្យប្រតិបត្តិសាសនារបស់ខ្លួន គឺមានអ្នកស្លាប់នៅក្នុងនោះគឺ ៣៣,៧ភាគរយ ប្រហែលជិតទៅនឹង២៥ភាគរយចំពោះប្រជាជននៅទាំងទូទៅ បើតាម ស្ទីវិនស្គី។ ហើយចំពោះជនកាតូលិកនោះ គឺមាន ៤៨,៦ ភាគរយ។ នេះ បើតាម ប៉ែន យៀរនិន។

[១១:៣១:៥០]

ចំពោះតួលេខនេះ ខ្ញុំមិនអាចនិយាយអ្វីវែងឆ្ងាយបានទេ ពីព្រោះថា យើងមិនមានអ្វីយកមកផ្ទៀងផ្ទាត់បាន។ អ៊ីចឹង គឺទាល់តែមានអ្នកជំនាញនេះមកផ្តល់សក្ខីកម្ម ទើបយើងអាចសួរដេញដោលគាត់ អំពីប្រភពបាន។ ទោះជាយ៉ាងណាក៏ដោយ ចំណុចនេះ គឺ ហង់រី ឡូកា គាត់បានបង្ហាញឲ្យឃើញថា យើងមិនអាចនិយាយថា កម្ពុជាប្រជាធិបតេយ្យមានឆន្ទៈ ក្នុងការប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ក្នុងការសម្លាប់រង្គាល ដោយសារតែមូលហេតុពូជសាសន៍នោះទេ ពីព្រោះថាហេតុការណ៍ដែលបានកើតឡើងនៅក្នុងកម្ពុជាប្រជាធិបតេយ្យនោះ វាកើតឡើងដោយសារតែការបង្ក្រាបខាងផ្នែកនយោបាយតែប៉ុណ្ណោះ។

ចំណុចមួយទៀត ដែលខ្ញុំចង់លើកឡើង -- លោកប្រធាន ខ្ញុំឃើញថាឥឡូវនេះ ម៉ោងដប់មួយសាមសិបនាទីហើយ ហើយខ្ញុំនៅសល់ឯកសារមួយចំនួនទៀតដែលត្រូវលើកឡើង និងបង្ហាញជូន។ ខ្ញុំមិនដឹងថាតើ លោកប្រធាន ឲ្យខ្ញុំបន្តទៀត ខ្ញុំប្រហែលជាត្រូវការ១៥ ទៅ២០នាទីទៀត។ អ៊ីចឹងខ្ញុំអាចបន្តពេលឈប់សម្រាកហើយក៏បាន លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះ ដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងមួយកន្លះរសៀលនេះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំង នាំខ្លួនលោក ខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញ នៅរសៀលនេះ ឲ្យបានមុនម៉ោងមួយកន្លះ។

បាទ សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:៣៣ នាទី ដល់ម៉ោង ១៣:៣២ នាទី)*

[១៣:៣២:១៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ។

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តី ខៀវ សំផន ដើម្បីបន្តការដាក់បង្ហាញឯកសារគន្លឹះរបស់ខ្លួននៅចំពោះមុខអង្គជំនុំជម្រះ។

**កញ្ញា អង់តា ហ្គីសសេះ**

សូមអរគុណលោកប្រធាន។ មុនពេលសម្រាកនេះ ខ្ញុំនិយាយអំពីឯកសារពីរដែលខ្ញុំចង់បង្ហាញជូនតុលាការដែលនិយាយអំពីការចរចាគ្នាជាមួយនឹងប្រទេសវៀតណាមនៅក្នុងឆ្នាំ១៩៧៦។ ឯកសារទី១ គឺឯកសារ E3/221 ដែលជាកំណត់ហេតុប្រជុំ ដែលមានចំណងជើងថា "ការសិក្សាពីប្រតិកម្មរបស់វៀតណាម ក្នុងកិច្ចប្រជុំថ្ងៃទី៥ ថ្ងៃទី១៥ ឧសភា ឆ្នាំ១៩៧៦"។ ឯកសារនេះ គឺជាការធ្វើប្លូកសរុបនៃការចរចាគ្នាជាមួយវៀតណាម ទាក់ទងនឹងបញ្ហាព្រំប្រទល់។ គេនិយាយអំពីបន្ទាត់ប្រេវីយ៉េ គឺព្រំដែនសមុទ្រហើយនិងបញ្ហាទាក់ទងទៅនឹងព្រំដែនគោកផងដែរ។

អ្វីដែលគួរឱ្យកត់សម្គាល់នៅក្នុងឯកសារនេះ គឺបើយើងមើលមួយក្រឡេកទៅគឺថា សមាជិកដែលចូលប្រជុំទាំងអស់នុ៎ង គឺថាត្រូវតែបន្តកិច្ចចរចាគ្នាទៅទៀត ហើយខ្ញុំសូមដកស្រង់នូវពីឯកសារដែលមាន ERN ជាភាសាបារាំងគឺ 00386180 ដល់ 81, ជាភាសាខ្មែរគឺ 00000815 ទៅដល់ 6, ERN ជាភាសាអង់គ្លេសគឺ 00182697 ទៅទំព័របន្ទាប់ទៀត។

សម្រង់នេះ ខ្ញុំអាននូវទំព័រទី១ គឺជាបទអន្តរាគមន៍របស់សមមិត្ត នួន ដែលគាត់និយាយអំពីការចរចាគ្នានុ៎ង។ គាត់ពន្យល់អំពីដំណើរការនៃកិច្ចចរចានុ៎ង ហើយមានអ្នកចូលរួមមានអ្នកណាខ្លះ។ គាត់ពន្យល់ដូចតទៅនេះ៖ "លទ្ធផលមិនសំខាន់ទេ គឺថាយើងត្រូវតែរក្សាគោលជំហរដដែលរហូត គោលជំហរបក្ស ហើយរក្សាបរិយាកាស ហើយនិងសាមគ្គី និងមិត្តភាពដដែលជាមួយវៀតណាម។ បើសិនជាបញ្ហាចរចានេះមិនប្រែប្រួលទេ បរិយាកាសវាអាចតឹងតែងជាងហ្នឹងទៅទៀត។ យើងអាចរកមធ្យោ-បាយដើម្បីឱ្យស្ថានការណ៍ហ្នឹងស្រាលទៅវិញ ហើយនិងចរចាគ្នាបន្តទៅទៀត។ ផាន់ ប៉ាន ហ្នឹងមិនមែនជាអ្នកនយោបាយឆ្លាតស៊ីជ្រៅនោះទេ វាជាអ្នកដែលលេងច្បាប់ ហើយគឺច្បាប់នាយទុនទៀតផង។

ចរចាជាមួយយើងដូចជាគេចរចាជាមួយអាមេរិកាំងអ៊ីចឹង។ វាប្រហែលជាមិនយល់អំពីមិត្តភាព ឬក៏សាមគ្គីភាពទេ។ វាចង់សង្កត់លើយើងក្នុងវិធីចរចា ហើយគាត់បន្ត -- នួន ជា បន្តទៀតគឺថា គណៈប្រតិភូវាហ្នឹងមានការបែងចែកគ្នាដែរ អ៊ីចឹងយើងត្រូវចាប់ដៃជាមួយសមាជិកវៀតណាមណាដែលត្រូវគ្នាជាមួយយើង ដើម្បីបំបែកវា។ អ៊ីចឹងបូកសរុបទៅការចរចាថ្ងៃនេះ វាមិនតឹងតែងណាស់ទេ។ វាជាការសម្ដែងគោលជំហរៀងៗខ្លួន ពីភាគីទាំងពីរនុំងតែប៉ុននុំងទេ។”

[១៣:៣៦:៤២]

ហើយទំព័របន្ទាប់ទៀត៖ “ជាការគួរឲ្យកត់សម្គាល់ដែរថា សុន សេន គាត់បានផ្ដល់យោបល់ពីការចរចាហ្នឹងដដែល ហើយគាត់និយាយអំពីស្ថានភាពយោធាផងដែរ។ គាត់លើកឡើងដូចតទៅនេះនៅកថាខណ្ឌទី៣ នៃបទអន្តរាគមន៍របស់គាត់។ គាត់និយាយ ដូច្នេះបើតាមប៉ាន់មើល មិនអាចសម្រេចសំណូមពរទី២, ទី៣, ទី៤ បានទេ យើងអាចរក្សាបរិយាកាសដដែលបាន តែម្នាក់ៗគេដឹងគោលជំហររបស់ខ្លួនហើយ។ បើសិនជាការចរចាគ្នាទៅទៀតហ្នឹងវានាំឲ្យតឹងតែងកាន់តែខ្លាំង។ ខ្ញុំយល់ស្របតាមសមមិត្ត នួន គួររកវិធីចរចាឲ្យសមស្រប។ ទាក់ទងទៅនឹងការដែលវៀតណាមបាញ់លើកប៉ាល់យើងនោះ មិនសូវសំខាន់អីទេ។ លើឆាកអន្តរជាតិវៀតណាមត្រូវការយើងដដែលទេ ដូច្នេះមិនមែនជាខ្លាំងក្លាអីណាស់ណាទេ។ យើងត្រូវរកវិធីបញ្ចប់ការចរចាយ៉ាងណាដើម្បីរក្សាបរិយាកាសឲ្យនៅដដែល។” ហើយគាត់បន្តទៀត នូវកថាខណ្ឌបន្ទាប់ទៀត ដោយលើកឡើងអំពីបញ្ហាអន្តរជាតិ ដោយសង្កត់ធ្ងន់លើសូមដកស្រង់៖ “វៀតណាមនិងថៃបានយកសមុទ្រយើងអស់ អ៊ីចឹងលំហសមុទ្រយើងហ្នឹងវាតូចណាស់ដូចខ្យងអ៊ីចឹង វៀតណាមនិងថៃយកអស់ហើយ”។ គាត់និយាយបន្តទៀត នៅទំព័រដដែល៖ “វៀតណាមមិនចំណេញទេ បើមានជម្លោះជាមួយចិនហ្នឹងកាន់តែធ្វើឲ្យវៀតណាមស្មុគទៀតហើយ។ ស្ថានការណ៍ឥឡូវនេះ បើសិនជាវាយកកោះយើងក៏វាលំបាកដែរ វាសម្លុតយើង ហើយវាមិនស្របច្បាប់ទេ។ យើងត្រូវធ្វើយ៉ាងណាឲ្យស្ថានភាពបន្ធូរវិញ ហើយរក្សាបរិយាកាសឲ្យនៅដដែល។”

នេះគឺជាព័ត៌មានទាក់ទងនឹងបរិបទដែលសំខាន់ណាស់ ពីព្រោះថាបើយើងគិតថានេះជាកំណត់ហេតុទាក់ទងនឹងការចរចានោះ យើងវាឃើញថា កម្ពុជាប្រជាធិបតេយ្យមានចេតនាចង់ចរចាដើម្បីធ្វើយ៉ាងណាឲ្យការចរចានេះនៅតែបន្តទៅទៀតជាមួយវៀតណាម។ សុន សេន បានលើកឡើងហើយថាទោះបីជាមានការបាញ់លើកប៉ាល់ក៏ដោយ ក៏ត្រូវតែចរចាជាមួយវៀតណាមទៀតដែរ។ ខ្ញុំប្រៀបធៀបឯកសារនេះទៅនឹងចម្លើយរបស់សាក្សីមួយចំនួនដែលបានមកផ្ដល់សក្ខីកម្ម ដែលបាននិយាយអំពីព្រំដែន

សមុទ្រ ហើយនិងអំពីបទបញ្ជាដែលគាត់បានទទួលពី សុន សេន ហើយនិងពីមេៗរបស់គាត់។

[១៣:៣៩:៤៨]

មានចំណុចមួយទៀតដែលខ្ញុំចង់លើកឡើងដែរ គឺនៅ ERN 00386187 ជាភាសាបារាំង។ ឯកសារនេះ និយាយអំពីការចរចា ហើយនិងរបៀបចរចាដែលបានប្រព្រឹត្តទៅ។ ហើយខ្ញុំនឹងបញ្ចប់នូវទំព័រចុងក្រោយនៃឯកសារដដែលហ្នឹង ដោយលើកឡើងអំពីការអន្តរាគមន៍របស់លេខា ប៉ុល ពត។ គាត់និយាយថា៖ “អ៊ីចឹង យើងត្រូវធ្វើឲ្យស្លូតឱន ហើយយើងទៅមើលកុនដែលប្រតិភូវៀតណាមបញ្ចាំងឲ្យមើល។ យើងមិនទាន់អាចសើចញញឹមអីដាក់គ្នាដោយស្មោះត្រង់បានទេ។ បើសិនវាវាយប្រហារយើង វាផ្ដាច់ទំនាក់ទំនងការទូត ចរចាជាមួយយើង វាមានតែខាតបង់ទេ។” អ៊ីចឹងយើងឃើញថា សូម្បីតែលេខា ប៉ុលពតហ្នឹង គាត់និយាយ គាត់ប្រាប់ពីរបៀបចរចាជាមួយវៀតណាមផងដែរ គឺថា គោលជំហរចរចាជាមួយរហូត ហើយកាលបរិច្ឆេទនៃការចរចានេះគឺសំខាន់ណាស់ពីព្រោះថា យើងនៅក្នុង -- មានគោលជំហរ បង្ហាញពីគោលជំហររបស់គណៈអចិន្ត្រៃយ៍នៅពេលហ្នឹង ដែលលើកឡើងអំពីភាពចាំបាច់នៃការបន្តការចរចាជាមួយវៀតណាមទៀត។ អ៊ីចឹងយើងមិនអាចបង្ហាញតាមរយៈឯកសារទាំងអស់នេះថា មានគោលនយោបាយមួយវាយប្រហារទៅលើវៀតណាមជាទូទៅនោះទេ ទោះបីជាផ្នែកយុទ្ធជន ក៏ដូចជាផ្នែកស៊ីវិលផងដែរ។

មានចំណុចមួយទៀត ដែលខ្ញុំចង់លើកឡើងដែរ គឺថា នៅទំព័រទី១ នៃឯកសារនេះ មានសរសេរថា “មានសមមិត្តខៀវ -- ហែម មានវត្តមានផងដែរ។ ក៏ប៉ុន្តែមិនឃើញមានការអន្តរាគមន៍របស់សមមិត្តហែម ទេ គាត់មិនបានបញ្ចេញមតិយោបល់អ្វីទេ។ ខ្ញុំសូមប្រៀបធៀបឯកសារនេះ ទៅនឹងឯកសារមុនមួយទៀតគឺថា កិច្ចប្រជុំគណៈរដ្ឋមន្ត្រីនៅក្នុងឆ្នាំ១៩៧៦ ខែ៥ គឺឯកសារ E3/794, ERNជាភាសាបារាំង គឺ 00611618, ERNជាភាសាខ្មែរគឺ 00000786, ជាភាសាអង់គ្លេសគឺ 00182676។

[១៣:៤២:៤២]

នេះគឺមិត្តលេខាបក្ស ដែលធ្វើការសង្ខេបសភាពការណ៍ ហើយគាត់លើកឡើងដូចតទៅនេះ។ កថាខណ្ឌចុងក្រោយជាភាសាបារាំង៖ “ទាក់ទងនឹងបញ្ហាព្រំដែន មិនមានដំណោះស្រាយអ្វីទេ បើតាមបទពិសោធន៍នៅលើពិភពលោកនេះ នៅកន្លែងខ្លះនោះ ត្រូវការរយៈពេលរាប់រយឆ្នាំ ដើម្បីដោះស្រាយបញ្ហាឲ្យចេញ។ ក៏ប៉ុន្តែសម្រាប់យើងវិញ យើងនៅតែបន្តដោះស្រាយបញ្ហាទាំងនេះទៀតនៅពេលចរចាបក្សបានលើកសំណួមពរបី ទី១ ថាបើសិនជាយើងរកដំណោះស្រាយមិនឃើញទេ ត្រូវតែរក្សាស្ថានភាព

នៅដដែល។ ទី២ បើសិនស្ថានភាពរីកចំរើនប្រសើរជាងមុន យើងត្រូវរក្សា ធ្វើទៅទៀត ហើយទី៣ ត្រូវតែរក្សាទំនាក់ទំនងដដែល។" នេះគឺនៅឆ្នាំ១៩៧៦ដដែល ដែលបញ្ជាក់អំពីគោលជំហរចង់ចរចាជាមួយវៀតណាម។

ទាក់ទងទៅនឹងបញ្ហាអ្វីដែលគេនិយាយទាក់ទងទៅនឹងប្រទេសវៀតណាម ថាតើនៅពេលណាមួយបក្សកុម្មុយនីស្តកម្ពុជាមានគោលនយោបាយអ្វីដែលធ្វើឲ្យ ថាចាត់ទុកវៀតណាមជាសត្រូវរបស់រដ្ឋមួយ ឬក៏ចាត់ទុកវៀតណាមជាបុគ្គលទេ ជាសត្រូវរបស់រដ្ឋ។ គឺលើកយកឯកសារ E3/744 ជាទង់បដិវត្ត ERN ជាភាសាបារាំងគឺ 00538944, ERNជាភាសាខ្មែរគឺ 00064440, ERNជាភាសាអង់គ្លេស គឺ 00464063។

[១៣:៤៤:៥៤]

បាទ ទង់បដិវត្តនេះគឺចុះនៅថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ១៩៧៨ ហើយបង្ហាញអំពីវៀតណាមក្នុងឋានៈជារដ្ឋ បើសិនជាមានជម្លោះអ្វីមួយ ជាមួយរដ្ឋនោះ គឺត្រូវគិតថា ជាជម្លោះរដ្ឋ មិនមែនគិតថាវៀតណាមជាពូជសាសន៍នោះទេ។ លេខ ERN ដែលខ្ញុំបានលើកឡើងអម្បាញ់មិញនេះ គឺមានសរសេរ --មានកាលវិភាគនៅក្នុងទង់បដិវត្ត។ នៅកថាខណ្ឌទី២ គឺថាបរាជ័យរបស់វៀតណាមខាងនយោបាយ។ ខ្ញុំរំលងកថាខណ្ឌទី១ ឥឡូវ ខ្ញុំចូលមកនិយាយអំពីអ្វីដែលយើងចាត់ទុកថា វាជាភាពទាល់ច្រកដែលវៀតណាមស្ថិតនៅ។ គឺថា វៀតណាមទាល់ច្រកមែនទែនហើយ មានការបរាជ័យផ្នែកនយោបាយមួយទៀតរបស់វៀតណាម គឺប្រជាជនវៀតណាមឃើញច្បាស់ថា នយោបាយឈ្លានពានគេ នាំឲ្យប្រទេស និងប្រជាជនវៀតណាមហិនហោចខ្លោចផ្សា។ មានចំណុចទី២មួយទៀត គឺថាមានគោលបំណងនយោបាយរបស់យួនមួយទៀត ដែលត្រៀមអង្គការមួយ ឬក៏បក្សមួយ ឬចលនាមួយរបស់យួន យកមកពីស្រុកយួនមកតាំង ឬក៏ប្រកាសនៅពេលដែលវាដណ្តើមដីកម្ពុជាបាន។ ផែនការនេះ គឺបរាជ័យទាំងស្រុងតែម្តងរបស់វៀតណាម។" ខ្ញុំសូមបញ្ចប់ការដកស្រង់។

នេះជាព័ត៌មានមួយសំខាន់ណាស់ ព្រោះថានៅក្នុងទង់បដិវត្តនេះ គឺថាយើងមានការបែងចែករវាងគោលនយោបាយរបស់វៀតណាមជាទូទៅ ហើយនិងប្រជាជនវៀតណាម ដែលយើងលើកឡើងនៅក្នុងនេះ ឃើញថាគោលនយោបាយឈ្លានពានគេនេះ មិនវិជ្ជមានទេ។ ប្រជាជនវៀតណាមឃើញខ្លួនឯងស្រាប់ហើយ។

[១៣:៤៦:៥១]

ហើយបន្ទាប់មកទៀត នៅក្នុងឯកសារដដែល គឺនៅកថាខណ្ឌចុងក្រោយ ជាភាសាបារាំងមានបញ្ជាក់កាន់តែច្បាស់ជាងនេះទៀតថា៖ “ជាសម្រាប់ប្រទេសវៀតណាមនោះជាការល្អ ក្នុងឋានៈជារដ្ឋហ្នឹង ល្អ ក៏ប៉ុន្តែសម្រាប់ពូជសាសន៍វៀតណាមមិនល្អទេ។ យើងបន្តទៀត គឺថាយើងព្យាយាមៗការពារយ៉ាងរឹងមាំ ហើយនិងលើកទង់បដិវត្ត និងទង់ឯករាជ្យ អធិបតេយ្យភាព ហើយនិងទង់ខ្លួន ទីពឹងខ្លួន។ លើកទង់ឯករាជ្យ អធិបតេយ្យភាពជាតិ ហើយនិងបូរណភាពដែនដី ហើយនិងទង់កិត្តិយសជាតិ និងប្រជាជនកម្ពុជាយើង។” នេះអ្វីដែលគួរឲ្យចាប់អារម្មណ៍ គឺថាការប្រៀបធៀបទៅនឹងទង់នោះ គឺថាសំខាន់ណាស់ ព្រោះជាទង់ជាតិ។ ហើយបន្តទៀតមានលើកឡើងថា៖ “យើងត្រូវតែវ៉ៃបំបាក់យ៉ាងខ្លាំងទង់ឈ្លានពាន វាតទី លេបទឹកដី។ វ៉ៃឲ្យបាក់ខ្លាំង ទង់សហព័ន្ធឥណ្ឌូចិនរបស់យួន។ វ៉ៃបំបាក់យ៉ាងខ្លាំងទង់ខ្លួបខ្លាចប្រទេសធំ តាមសហភាពនិយម វ៉ៃបំបាក់យ៉ាងខ្លាំងទង់លិទ្ធិប្រទេសធំរបស់យួន។ ទង់បក្សតែមួយ ប្រទេសតែមួយ ប្រជាជនតែមួយរបស់យួន ក៏ត្រូវតែបំបាក់យ៉ាងអាម៉ាស់បំផុតផងដែរ។” សូមបញ្ចប់ការដកស្រង់។

[១៣:៤៨:៣៣]

ជាថ្មីម្តងទៀត ដើម្បីធៀបទៅនឹងអ្វីដែលខ្ញុំបានលើកឡើងអម្បាញ់មិញនេះ គឺថាមានភាពធ្វើឡើងដដែលៗ គឺថាបញ្ហារបស់រដ្ឋវៀតណាមដើម្បីដាក់ប្រទេសកម្ពុជាជាឧបសម្ព័ន្ធ។ ប្រទេសវៀតណាមដែលចង់លេបទឹកដីកម្ពុជា អធិបតីភាពកម្ពុជា ក៏ប៉ុន្តែមិនមែនសំដៅទៅលើជនជាតិវៀតណាម ឬក៏ប្រជាជនវៀតណាមទេ សំដៅលើរដ្ឋទេ។ អ៊ីចឹង ត្រូវបែងចែកឲ្យច្បាស់ចំណុចនេះ។ ដូច្នេះ នៅក្នុងទង់បដិវត្តនេះ ចុះខែ០២ ឆ្នាំ១៩៧៨។

ដើម្បីបញ្ចប់ការជាមួយនឹងឯកសារមួយចំនួនដែលយើងចង់បង្ហាញផងដែរ គឺអម្បាញ់មិញនេះយើងបានលើកឡើងអំពីបញ្ហាព្រំប្រទល់ជាមួយនឹងប្រទេសវៀតណាម ហើយនិងចលនាមួយចំនួនផ្សេងៗ ដែលបានមានរៀបរាប់នៅក្នុងសារព័ត៌មាន គឺចលនារំដោះជាតិ ហើយនិងចលនាបះបោរនៅក្នុងនិងក្រៅប្រទេសជាដើម។

យើងមានអត្ថបទមួយចំនួនទៀត គឺអត្ថបទកាសែតពីរទៀត ទាក់ទងនឹងបញ្ហានេះ ហើយដែលទាក់ទងទៅនឹងអតីតទាហានសាធារណរដ្ឋខ្មែរ។ អត្ថបទទាំងអស់នេះ និយាយអំពីចលនាបះបោរ ឬក៏ការប៉ុនប៉ងចង់ត្រឡប់ទៅប្រទេសកម្ពុជាវិញ ដើម្បីផ្តួលរំលំរបបកម្ពុជាប្រជាធិបតេយ្យ ហើយដែលកងទ័ពទាំងអស់នេះដែលដឹកនាំដោយអតីតទាហាន លន់ នល់។ ខ្ញុំសូមដកស្រង់ឯកសារទី១ គឺឯកសារ

E3/7314 ដែលជាអត្ថបទកាសែត *លីបប៊ីរ៉ាស្យុង* ខែមិថុនា ឆ្នាំ១៩៧៦។ នេះ កាលបរិច្ឆេទនេះសំខាន់ណាស់។ នេះមិនមែនជាចលនាដែលកើតនៅព្រំប្រទល់វៀតណាមនោះទេ ក៏ប៉ុន្តែនៅព្រំប្រទល់ថៃ។ នៅក្នុងអត្ថបទនេះ គេនិយាយ -- បាទ នៅ ERN ជាភាសាបារាំងគឺ -- មានតែជាភាសាបារាំងទេ អត្ថបទនេះ ERN F00005779 ដែលគេនិយាយអំពីម៉ូលីណា នៅកថាខណ្ឌ នៅចំកណ្ដាលទំព័រ មាននិយាយថា នៅក្នុងព្រៃនុំង គឺថាមានមនុស្សជាច្រើនដែលតំណាងឲ្យចលនាប្រឆាំងនឹងខ្មែរក្រហម ដែលតាមពិតទៅ គាត់ជាទាហានស៊ីឈ្នួលទេ ហើយអ្នកកាសែតដែលសរសេរអត្ថបទកាសែតនេះ បានលើកឡើងដូចតទៅនេះ៖ "ក្រៅពីក្រុមទាំងអស់នេះ ដែលចលនាតស៊ូហាក់ដូចជាមធ្យោបាយបន្ទាប់បន្សំ ដើម្បីចំណេញលុយ គឺមានក្រុមផ្សេងៗទៀត ដែលអាស្រ័យទៅអ្នកនយោបាយផ្សេងៗ ឬក៏អាស្រ័យនឹងឧត្ដមសេនីយ៍នៃរបបចាស់មួយចំនួន ដែលឃើញថាការតស៊ូនេះ គឺធ្វើឲ្យចំណេញប្រាក់កាក់ ហើយនិងធ្វើយ៉ាងណាដើម្បីទាមទារយកប្រយោជន៍របស់ខ្លួនមកវិញ។ ក្រុមទាំងអស់នេះៗមានចំនួនតិចណាស់ ហើយមិនមានសកម្មភាពអីនោះទេ។ ពួកគេចេះបែកខ្ញែកពីគ្នា ដោយសារពុករលួយខ្លាំងជាដើម ក្នុងចលនារបស់ពួកគេនេះ។ នៅខែមេសា នៅទីក្រុងប៉ារីស មានការប្រកាសប្រមូលផ្ដុំក្រុមតស៊ូទាំងអស់នេះ នៅក្រោមឈ្មោះថា ម៉ូលីណា គឺចលនារំដោះជាតិខ្មែរ ដែលប្រកាសនៅ ដែលមាន អ៊ិន តាំ ហើយនិង សឹង ង៉ុកថាញ់ ដែលពួកគាត់ទាំងពីរនោះ និរទេសខ្លួននៅប្រទេសបារាំង។ នៅអារញ្ញប្រថេត អ្នកដឹកនាំចលនាទាំងអស់នេះនៅនឹងកន្លែង គឺមានអតីតរដ្ឋមន្ត្រីសម័យខ្មែរសាធារណរដ្ឋនុំងមួយ ហើយនិងមនុស្សពីរនាក់ទៀតដែលគាត់ជាអ្នកគ្រប់គ្រងចលនាទាំងអស់ -- ដឹកនាំចលនាទាំងអស់នេះ។

[១៣:៥៣:០៧]

ទាក់ទងទៅនឹងអ្នកដែលចេញពីពាក្យចចាមអារ៉ាម សម្រាប់ -- ចំពោះអ្នកតស៊ូដែលនៅភ្នំ -- ជួរភ្នំក្រវាញនោះ មិនមានព័ត៌មានច្បាស់លាស់នោះទេ មិនដឹងថាគេនៅកន្លែងណាទេ ពីព្រោះថា ចូលទៅក្នុងព្រៃជួរភ្នំក្រវាញនេះ ពិបាកណាស់។ ក៏ប៉ុន្តែចំនួនក្រុមតស៊ូទាំងអស់នេះ មិនលើសពី២០.០០០នាក់ទេ។ មានក្រុមតែមួយទេ ដែលមានសកម្មភាពជាងគេ គឺក្រុមរំដោះជាតិកម្ពុជា ដែលមានការហ្វឹកហ្វាត់ត្រឹមត្រូវ មានបំពាក់ប្រដាប់អាវុធត្រឹមត្រូវ ដែលចូលទៅក្នុងទឹកដីប្រទេសខ្មែរ ហើយដែលមានមូលដ្ឋាននៅប្រទេសថៃ នៅព្រំប្រទល់ថៃ។ ក្រុមទាំងអស់នេះ មាននៅក្នុងក្រុមហ្នឹង គឺថាមានអតីតទាហានលន់ នល់ ហើយមានរៀបចំរចនាសម្ព័ន្ធត្រឹមត្រូវ ហើយនិងផ្ដល់ការជំនួយដូចជា ឧបករណ៍ ជាសម្ភារៈផ្សេងៗ ពីថៃ។ នេះជាបរិបទដែលធ្វើឲ្យយើងអាចយល់អំពីខ្មាំងដែលធ្វើសកម្មភាពនៅព្រំប្រទល់ថៃ

ជាដើម ដែលមានព័ត៌មានដែលចេញពីប្រទេសថៃមក ឲ្យយើងដឹងថាមានចលនាទាំងអស់នេះ។ នេះ គឺជាព័ត៌មានដែលគេយកទៅរាយការណ៍បន្តទេ នៅគេចុះផ្សាយនៅក្នុងបាងកកប៉ុស្តិ៍ ឯកសារ E3/7316 ចំណងជើងអត្ថបទនេះ គឺជាភាសាអង់គ្លេសទេ។ ខ្ញុំគិតថា មានតែជាភាសាអង់គ្លេសទេ។ អត្ថបទនេះមានចំណងជើង -- គឺនិយាយអំពីចលនាប្រឆាំងទៅនឹងកុម្មុយនីស្តនៅក្នុងប្រទេសកម្ពុជា ហើយពួកឧទ្ទាមប្រឆាំងទៅនឹងចលនាកុម្មុយនីស្តហ្នឹងបាននិយាយប្រាប់ទៅនឹងកាសែតអាហ្សង់ហ្វ្រង់ប្រេស៖ “មេដឹកនាំ គឺជាអ្នកដែល -- គឺមកពីទាហានរបបសាធារណរដ្ឋនៅពេលដែលសេនាប្រមុខ លន់ នល់ គ្រប់គ្រងប្រទេសកម្ពុជា។ និយាយថា អង្គការហ្នឹង គឺជាអង្គការរំដោះជាតិកម្ពុជា ដែលមានក្រុមមនុស្សប្រហែលជា២០ទៅ៣០នាក់ ដែលនៅតាមបណ្តោយព្រំដែនថៃ និង នៅទន្លេសាប។ យោងតាមមេដឹកនាំនេះ គឺថារណសិរ្សរំដោះនេះ គឺមានកងទ័ពដែលជាឧទ្ទាមហ្នឹង២០០នាក់ ប្រដាប់ដោយអាវុធ ហើយពួកគេគឺថាមានការធ្វើចលនាជាបន្តបន្ទាប់ទៅទៀតនៅភូមិភាគបស្ចិម -- ភូមិភាគពាយ័ព្យ។ រណសិរ្សនេះ គឺថាមានចលនាប្រតិបត្តិការនៅទិសខាងលិចឈ្មោះម៉ូលីណា សហការគ្នាជាមួយចលនាមួយទៀតឈ្មោះម៉ូលីណា។ នេះគឺជាសម្តីរបស់មេដឹកនាំ។ ម៉ូលីណា មានបណ្តាញរបស់ខ្លួននៅប៉ារីស ហើយធ្វើការទាក់ទងជាប្រចាំនៅក្នុងប្រទេស។ តំបន់រំដោះតូចៗត្រូវបង្កើតរួចហើយនៅភាគខាងត្បូង នៅជិតប៉ោយប៉ែត ឆ្លងពីព្រំដែនថៃមក។ នេះបើតាមសម្តីរបស់មេដឹកនាំ។ គឺមេដឹកនាំហ្នឹង មានចម្ងាយប្រហែលជា១០០គីឡូម៉ែត្រពីព្រំដែន។” បញ្ចប់ការដកស្រង់។

[១៣:៥៧:១៨]

ក្នុងអត្ថបទនេះបន្តទៀតហ្នឹង គឺមានលើកឡើងអំពីអ្វីដែលគេលើកឡើង ហើយនិងអ្វីដែលកើតឡើងនៅតាមព្រំប្រទល់ នៅក្នុងឆ្នាំ១៩៧៦ ហ្នឹងមានការចោទប្រកាន់ថា មានការបះបោរហើយនិងការវាយប្រហារគ្នាទៅលើរបបកម្ពុជាប្រជាធិបតេយ្យនៅភូមិភាគពាយ័ព្យ គឺថាកងកម្លាំងតស៊ូទាំងអស់នេះ គេចូលមកវាយនៅតាមព្រំប្រទល់។ អ៊ីចឹងយើងត្រូវយល់ផងដែរ គឺថាការដែលមានការវាយប្រហារទាំងអស់នេះ គឺធ្វើឲ្យខាងរដ្ឋាភិបាលក្រុងភ្នំពេញ ទទួលរងការប៉ះពាល់ហើយ។ អ៊ីចឹងខ្ញុំសូមប្រៀបធៀបទៅនឹងឯកសារមួយទៀត គឺឯកសារ E3/7290 គឺទំព័រទី១ ដែលអត្ថបទរបស់អ្នកស្រាវជ្រាវម្នាក់ដែលមកពីសាកលវិទ្យាល័យយែល ជាការងាររបស់អ្នកស្រាវជ្រាវ។ អ្វីដែលគួរឲ្យចាប់អារម្មណ៍នោះ គឺថា ERN ជាភាសាបារាំងគឺ 01172718, ERN ជាភាសាខ្មែរ 01152710, ERN ជាភាសាអង់គ្លេសគឺ 00993809។ អ្នកស្រាវជ្រាវនេះ បាននិយាយអំពីបញ្ហាព្រំប្រទល់ជាមួយប្រទេសថៃគឺនៅកថាខណ្ឌចុង

ក្រោយនៃអត្ថបទជាភាសាបារាំង។ ជម្លោះព្រំប្រទល់នេះ គឺបណ្ដាលមកពីការទាមទារជាបន្តបន្ទាប់ពីប្រទេសថៃ ពីប្រទេសកម្ពុជាទាក់ទងទៅនឹងបញ្ហាព្រំប្រទល់។ គេយល់ឃើញថា វាជា -- វាកើតចេញពីការធ្វើសង្គ្រាមឈ្លបពីខាងសាធារណរដ្ឋ ដែលនៅ ដែលរស់នៅតាមព្រំប្រទល់ថៃដែលធ្វើជាមូលដ្ឋានជ្រកកោនរបស់ខ្លួន។

[១៣:៥៩:៣០]

កម្លាំងនេះ គេហៅកម្លាំងខ្មែរសេរីដែលមានអតីតយោធា លន់ នល់ ជាសមាជិក ហើយមាន អ៊ិន តាំ ដែលមានមូលដ្ឋាននៅតាមព្រំប្រទល់ ដូចតាមចាន់បូរី ហើយនិងបាត់ដំបង ចន្លោះចាន់បូរី និងបាត់ដំបង។ នេះ គឺជាចំណុចចុងក្រោយដែលនិយាយអំពីជម្លោះ ហើយនិងការវាយលុកពីព្រំប្រទល់ថៃចូលមកប្រទេសកម្ពុជា។

អ៊ីចឹងខ្ញុំសូមបញ្ចប់ការបង្ហាញឯកសារត្រឹមណេះ ហើយខ្ញុំនឹងត្រឡប់មកឆ្លើយតបទៅខាងព្រះរាជអាជ្ញាម្ដងទៀតនៅថ្ងៃសុក្រ លោកប្រធាន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សវនាការនៅថ្ងៃនេះដល់ពេលឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃសុក្រទី២៦ ខែកុម្ភៈ ឆ្នាំ ២០១៦ ចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។ ហើយសវនាការនៅថ្ងៃសុក្រចុងសប្ដាហ៍នេះ អង្គជំនុំជម្រះនឹងបន្តធ្វើសវនាការបង្ហាញឯកសារគន្លឹះ ពាក់ព័ន្ធនឹងអង្គហេតុការប្រព្រឹត្តទៅលើក្រុមមនុស្សគោលដៅជាក់លាក់ចំពោះជនជាតិចាម ចំពោះជនជាតិវៀតណាម ហើយនិងចំពោះអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ។

ហើយដោយការស្ដាប់នូវតំណាងសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីតប ឬក៏កត់សម្គាល់ទៅនឹងបណ្ដាឯកសារគន្លឹះ ដែលបានដាក់បង្ហាញដោយសហមេធាវីការពារក្ដី ខៀវ សំផន ហើយនិងស្ដាប់ការធ្វើការឆ្លើយតប ឬការកត់សម្គាល់ពីសំណាក់សហមេធាវីការពារក្ដី ខៀវ សំផន ទៅនឹងបណ្ដាឯកសារគន្លឹះដែលបានដាក់បង្ហាញដោយសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។

ហើយសូមបញ្ជាក់ថា ថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងមិនធ្វើសវនាការទេ ដោយទុកពេលវេលាសមស្រប ដើម្បីឲ្យភាគីមានលទ្ធភាពរៀបចំនូវសេចក្ដីតប ឬក៏ការកត់សម្គាល់តបទៅនឹងបណ្ដាឯកសារ

គន្លឹះពាក់ព័ន្ធនឹងអង្គហេតុដូចខាងលើនេះ ដែលបានដាក់បង្ហាញដោយភាគីម្ខាងទៀត។ ហើយសូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន និងលោក នួន ជា ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅថ្ងៃសុក្រ ទី២៦ ខែកុម្ភៈ ឆ្នាំ២០១៦ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៤:០១ នាទី)*